**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Driot et des Sciences Economiques
Royal University of Law and Economics

**សារណាបញ្ចប់ការសិក្សា**

# កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ នៅប្រទេសកម្ពុជា

ស្រាវជ្រាវនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២ ដល់ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ ក. **ឈៀង លីណា**
ក. **អឿន ស្រីនិច**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ឃឹម ម៉ាណែត**

ថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈ
ជំនាន់ទី១៥

ឆ្នាំចូលសិក្សា ២០១៨
ឆ្នាំសរសេរសារណា ២០២២

# **សេចក្ដីថ្លែងអំណរគុណ**

នាងខ្ញុំឈ្មោះ **ឈៀង លីណា** និងឈ្មោះ **អឿន ស្រីនិច** ជានិស្សិតថ្នាក់បរិញ្ញាបត្រឆ្នាំទី៤ ជំនាញរដ្ឋបាលសាធារណៈ នៃសាកលវិទ្យាល័យភូមិនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២១-២០២២។

**យើងខ្ញុំសូមគោរព និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ៖**

**លោកឪពុក អ្នកម្ដាយ** ដែលលោកទាំងពីរបានផ្ដល់កំណើត និងចិញ្ចឹមថែរក្សាបីបាច់ទូន្មានប្រៀនប្រដៅទំនុកបម្រុង និងផ្ដល់ដំបូន្មានល្អៗដល់រូបកូនអោយកូនបានរៀនសូត្រ។ លោកទាំងពីរ បានខិតខំប្រឹងប្រែងទាំងយប់ទាំងថ្ងៃហាលខ្យល់ហាលភ្លៀង ដើម្បីរកប្រាក់អោយកូនបានរៀន តាំងពីថ្នាក់ទាបរហូតដល់បានបញ្ចប់ថ្នាក់បរិញ្ញាបត្រនៅសាកលវិទ្យាល័យជាស្ថាពរ។ ទឹកចិត្តរបស់លោកទាំងពីរ ធ្វើឲ្យកូនមិនអាចបំភ្លេចបានឡើយ និងរិតតែមិនអាចឲ្យកូនបំភ្លេចនូវគុណូបការៈ ដ៏សែនធំរបស់លោកទាំងពីររហូតដល់ដង្ហើមចុងក្រោយ។ ខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងសូមបួងសួងដល់គុណព្រះរតនត្រ័យមេត្តាតាមជួយថែរក្សាលោកអ្នកមានគុណទាំងពីរទទួលបានតែសេចក្ដីសុខចម្រើន និងជាម្លប់ដ៏ត្រជាក់ត្រជំដល់កូនជានិច្ច។

**ឯកឧត្ដមសាកលវិទ្យាធិការ** រួមទាំងលោក លោកស្រីដែលជាសាស្ត្រាចារ្យ បុគ្គលិកការិយាល័យនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រសេដ្ឋកិច្ចទាំងអស់បានជួយជ្រោមជ្រែងគ្រប់បែបយ៉ាងក្នុងការជួយឲ្យយើងខ្ញុំ មានលទ្ធភាពងាយស្រួលក្នុងការសិក្សាកន្លងមកនេះ។

**អ្នកគ្រូសាស្ត្រាចារ្យ យឹម ម៉ាណែត** ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ និងផ្ដល់គំនិតល្អៗដល់យើងខ្ញុំក្នុងតាក់តែងសៀវភៅនេះឡើង។ ប៉ុន្តែបើគ្មានវត្តមានរបស់អ្នកគ្រូសាស្ត្រាចារ្យទេប្រហែលជាខ្ញុំមិនអាចសម្រេចបាននូវស្នាដៃមួយនេះបាននោះទេ គឺក៏ព្រោះតែបានអ្នកគ្រូសាស្ត្រាចារ្យដែលបានចំណាយពេលវេលាដែលមានតម្លៃ ក្នុងការពិនិត្យ និងកែលម្អនូវសារណាមួយនេះឲ្យមានលក្ខណៈល្អប្រសើរ។

ជាចុងក្រោយនៃអត្ថបទនេះ យើងខ្ញុំទាំងពីរអ្នកសូមគោរពប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គល កើតមានដល់លោកអ្នកមានគុណទាំងអស់ សូមឱ្យលោកជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ក្រោយពីការសិក្សាអស់រយៈពេលបួនឆ្នាំកន្លងមកនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ផ្នែករដ្ឋបាលសាធារណៈ ក្រោមការបង្ហាត់បង្រៀនរបស់លោកលោកស្រី សាស្ត្រាចារ្យដែលមានបទពិសោធន៍យ៉ាងស្ទាត់ជំនាញនៅក្នុងការបង្ហាត់បង្រៀន។ នៅក្នុងឆ្នាំចុងក្រោយ នៃការសិក្សា ហើយក៏ជាឆ្នាំដែលយើងខ្ញុំត្រូវឈានជើងដើរចេញពីសាកលវិទ្យាល័យនៅពេលខាងមុខ យើងខ្ញុំបានជ្រើសរើសយកប្រធានបទមួយមកធ្វើការសិក្សាស្រាវជ្រាវ គឺ "**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅប្រទេសកម្ពុជា**"។ នេះជាសក្ខីភាព និងជាស្នាដៃមួយសម្រាប់ជំនួយដល់ការសិក្សាស្រាវជ្រាវរបស់និស្សិតជំនាន់ក្រោយៗ ទៀតក្នុងការចងក្រងជាសារណាបញ្ចប់ការសិក្សានេះឡើង គឺអាស្រ័យដោយមានការណែនាំពី សំណាក់អ្នកគ្រូ **យឹម ម៉ាណែត** ដែលបានខិតខំប្រឹងប្រែងជួយជំរុញ ដូចជាជួយបង្ហាញពីវិធីសាស្ត្រនានា ក្នុងការធ្វើយ៉ាងណាដើម្បីសម្រេចបានជាសារណានេះឡើង។

ផ្អែកលើការអនុវត្តកំណែទម្រង់នេះ ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអភិវឌ្ឍន៍ដំណើរការការិយាល័យ និងអង្គភាពនានា។ ដូចគ្នាដែរ ក្នុងការសិក្សាស្រាវជ្រាវនេះបានស្វែងយល់អោយកាន់តែច្បាស់នូវដំណើរការនៃការអនុវត្តន៍ប្រព័ន្ធរដ្ឋបាលនៅក្នុងប្រទេស បន្ទាប់ពីធ្វើការកំណែទម្រង់រួច។ ជាពិសេសនោះការបន្តស្វែងយល់នូវចន្លោះខ្វះខាតក្នុងការកែលម្អបន្តបន្ទាប់ដើម្បីអោយដំណើរការការងារកាន់តែមានប្រសិទ្ធភាព។ ជារួមមករដ្ឋបាលដែលល្អសំរាប់ប្រជា-ពលរដ្ឋគឺជាការបំរើប្រជាពលរដ្ឋអោយចំគោលដៅល្អ ស្មោះត្រង់ រួសរាយរាក់ទាក់ ព្រមទាំងខិតជិតពួកគាត់ដើម្បីអោយកាន់តែឆាប់រហ័ស។

នាងខ្ញុំទាំងពីរពិតជាមានសេចក្តីសោមនស្សរីករាយជាពន់ពេក ដែលមានឱកាសក្នុងការចងក្រងនូវសារណាមួយនេះឡើងក្រោមការជួយជ្រោមជ្រែងពីលោកសាស្ត្រាចារ្យ និងមិត្តនិស្សិតគ្រប់ជំនាន់។ ជាចុងក្រោយនាងខ្ញុំសូមប្រសិទ្ធិពរ និងជូនដល់លោកគ្រូ អ្នកគ្រូសាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ជួបតែសេចក្តីសុខគ្រប់ប្រការ និងទទួលរាប់អានពីនាងខ្ញុំ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម** ........................................................................................................ ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........................................................................................ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ....................................................................................២

៣. គោលបំណងនៃការស្រាវជ្រាវ ......................................................................................២

៤. ទំហំដែនកំណត់នាំការស្រាវជ្រាវ ..................................................................................២

៥. សារៈសំខាន់នៃការស្រាវជ្រាវ ......................................................................................២

៦. វិធីសាស្រ្តនៃការស្រាវជ្រាវ ..........................................................................................៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........................................................................................ ៣

**ជំពូកទី១**

**ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

**១.១ អត្ថន័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** ...............................................៤

១.១.១ ការធ្វើប្រតិភូតកម្មអំណាច ........................................................................................ ៥

១.១.២ ការធ្វើប្រតិកម្មភូតកម្មហត្ថលេខា ............................................................................... ៥

**១.២ គុណសម្បត្តិ និងគុណវិបត្តិ** .................................................................................... ៦

១.២.១ វិមជ្ឈការ................................................................................................................ ៦

១.២.២ វិសហមជ្ឈការ ......................................................................................................... ៧

**១.៣ គោលដៅ**.............................................................................................................. ៧

**១.៤ គោលបំណង** ........................................................................................................... ៨

**ជំពូកទី២**

**ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

**២.១ រចនាសម្ព័ន្ធ** .............................................................................................................. ៩

**២.២. ក្របខណ្ឌគោលនយោបាយ និងច្បាប់** ........................................................................ ៩

២.២.១ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤........................................ ១១

២.២.២ ក្របខណ្ឌយុទ្ធសាស្រ្តចតុកោណស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ........................ ១១

២.២.៣ ច្បាប់រៀបចំអង្គការ................................................................................................. ១២

**២.៣ កំណែទម្រង់ថ្នាក់ជាតិ** ............................................................ ១២

**២.៤ កំណែទម្រង់ថ្នាក់ក្រោមជាតិ** ............................................................ ១៥

២.៤.១ ការអនុវត្តន៍ភារកិច្ចរបស់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ........................ ១៥

២.៤.១.១ ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ ........................ ១៥

២.៤.១.២ តួនាទី និងភារកិច្ចក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ........................ ១៧

២.៤.១.៣ សិទ្ធិអំណាចក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ........................ ២០

២.៤.១.៤ កិច្ចប្រជុំការងារក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ........................ ២១

២.៤.២ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ........................ ២២

២.៤.២.១ តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់ ........................ ២២

២.៤.២.២ ផែនការអភិវឌ្ឍរដ្ឋបាលឃុំ សង្កាត់ ........................ ២៤

២.៤.២.៣ ទោសប្បញ្ញត្តិ ........................ ២៥

២.៤.៣ គោលការណ៍នៃប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ........................ ២៧

២.៤.៣.១ ការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ ........................ ៣០

២.៤.៣.២ ការបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ........................ ៣១

**ជំពូកទី៣**

**លទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ**

**នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ**

**៣.១ លទ្ធផលដែលទទួលបានក្នុងការអនុវត្តកន្លងមក** ........................ ៣៣

**៣.២ បញ្ហាប្រឈម** ........................ ៣៥

**៣.៣ ដំណោះស្រាយ** ........................ ៣៧

**សេចក្តីសន្និដ្ឋាន** ........................ ៣៩

**អនុសាសន៍** ........................ ៤០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ផ្អែកតាមប្រវត្តិសាស្ត្រ ប្រទេសកម្ពុជាជាប្រទេសដែលកកើតឡើងតាំងពីសតវត្សទីមួយមកម្លេះ។ ជាងនេះទៅទៀតប្រទេសកម្ពុជា ជាប្រទេសដែលមានភាពរីកចម្រើន និងសម្បូរទៅដោយធនធានធម្មជាតិ។ ដោយហេតុឆ្លងកាត់នូវសង្គ្រាម ជម្លោះក្នុងប្រទេសដើម្បីដណ្តើមអំណាច និងការដាក់អាណានិគមពីប្រទេសដទៃ ធ្វើអោយភាពរីកចម្រើន និងការលូតលាស់ប្រទេសធ្លាក់ចុះជាខ្លាំង។ ជាលទ្ធផលក្រោយពីឆ្លងកាត់សម័យកាលជាច្រើនមក ប្រទេសកម្ពុជារងនូវការបំផ្លាញ និងការបាត់បង់ជាច្រើនដូចជា អ្នកប្រាជ្ញ វត្ថុបុរាណ ប្រាសាទបុរាណ និងការខូចខាតហេដ្ឋារចនាសម្ព័ន្ធជាច្រើនទៀត។

បន្ទាប់ពីទទួលបានសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដីពេញលេញនៅចុងឆ្នាំ១៩៩៨តាមរយៈនយោបាយឈ្នះ ឈ្នះ រាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តន៍កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នាឆ្នាំ២០០២ និងពង្រីកវិសាលភាពនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេសនាឆ្នាំ២០០៩។ ប្រទេសកម្ពុជាប្រៀបដូចជាប្រទេសទើបកកើតថ្មី ដោយហេតុត្រូវចាប់ផ្តើមគ្រប់ផ្នែកទាំងអស់ពីចំណុចសូន្យ។ ក្នុងនោះដែរកត្តាសំខាន់ក្នុងការស្តារប្រទេសឡើងវិញនោះគឺការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលដែលបែងចែកជាថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីខិតជិតប្រពលរដ្ឋ និងប្រព្រឹត្តទៅដោយប្រសិទ្ធិភាព តម្លាភាពជូនប្រជាពលរដ្ឋ។

ជាការពិតណាស់ ការអនុវត្តន៍វិធានការវិមជ្ឈការ និងវិសហមជ្ឈការបានសម្រួលការងារជូនប្រជាពលរដ្ឋអោយកាន់តែឆាប់រហ័ស។ ជាពិសេសនោះបានស្វែងយល់ ថាតើប្រជាពលរដ្ឋចង់បានអ្វី និងព្រមទាំងទទួលបាននៅមតិយោបលរបស់ពួកគាត់យកមកអភិវឌ្ឍប្រទេសជាតិ។ កត្តាទាំងនេះធ្វើអោយប្រទេសមានភាពរីកចម្រើនយ៉ាងឆាប់រហ័សដើម្បីឈានដល់ការទទួលស្គាល់ពីអន្តរជាតិ។

ហេតុដូច្នេះហើយ ដើម្បីស្វែងយល់ពីនិតិវិធី ក៏ដូចជាលទ្ធផលដែលទទួលបានពីដំណើរការនៃការប្រើប្រាស់កំណែទម្រង់នេះ ទើបក្រុមយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសយកប្រធានបទមួយស្តីពី "កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ" យកមកធ្វើការសិក្សាស្រាវជ្រាវ ដោយផ្តោតសំខាន់ទៅលើនិតិវិធី និងដំណើរការនៃការអនុវត្តន៍នៅតាមតំបន់មួយៗ។ ប្រធានបទនេះនឹងផ្តល់ខ្លឹមសារ និងផលប្រយោជន៍ដល់ប្រជាពលរដ្ឋ ក៏ដូចជាមន្ត្រីរាជការថ្នាក់មូលដ្ឋាន និងព្រមទាំងចូលរួមជាចំណែកនៃឯកសារសម្រាប់និស្សិតជំនាន់ក្រោយសិក្សាស្រាវជ្រាវ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើតជំរុញ និងធ្វើអោយមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ តាមរយៈនយោបាយ វិមជ្ឈការ និងវិសហ-មជ្ឈការ ដែលជាកំណែទម្រង់មួយដ៏មានសារៈសំខាន់បំផុត ក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព មានការចូលរួមពីប្រជាពលរដ្ឋក្នុងការបញ្ចេញមតិ គណនេយ្យភាព សមធម៌ និងបរិយាប័ន្ន។ ប៉ុន្តែមានមនុស្សមួយចំនួននៅមិនទាន់ច្បាស់នៅឡើយពាក់ព័ន្ធអត្ថន័យ និងដំណើរការ ទើបមានចោទជាសំណួរដូចខាងក្រោម៖

១.តើវិមជ្ឈការ និងវិសហមជ្ឈការមានន័យដូចម្តេច?

២.តើគេប្រើយុត្តិសាស្ត្រអ្វីខ្លះក្នុងការគាំទ្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ?

៣.តើការអនុវត្តន៍ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការទទួលបានលទ្ធផលដូចម្តេច?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងសំខាន់នូវក្នុងការសិក្សាស្រាវជ្រាវនេះគឺ៖

ទី១ ដើម្បីស្វែងយល់ពីអត្ថន័យ និងគោលបំណងនៃការដាក់អោយអនុវត្តនូវគោលនយោបាយ វិមជ្ឈការ និងវិសហមជ្ឈការ។

ទី២ ដើម្បីស្វែងយល់ពីដំណើរការ និងការប្រើប្រាស់យុត្តិសាស្ត្ររបស់រាជរដ្ឋាភិបាល។

ទី៣ ដើម្បីសិក្សាពីលទ្ធផលដែរទទួលបានពីការដាក់អោយអនុវត្តនៅតាមថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

## ៤. ទំហំដែនកំណត់នៃការស្រាវជ្រាវ

ការកំណត់នៅដែនកំណត់នូវការស្រាវជ្រាវ និងមិនធ្វើឱ្យការបកស្រាយមានការចាកប្រធាន ឬលើសដែនកំណត់ ។ ដូច្នេះសម្រាប់ប្រធានបទស្តីពី " កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ " នេះ ខ្ញុំនឹងសូមធ្វើការបកស្រាយទៅលើ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ អំពីសិទ្ធិអំណាច តួនាទី ភារកិច្ច បញ្ហា និងដំណោះស្រាយដែលកើតមានឡើងក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

លទ្ធផលដែលទទួលបានក្នុងការស្រាវជ្រាវនេះ ដើម្បីយល់នឹងពីការធ្វើកំណែទម្រង់វិមជ្ឈការ និងវិស -ហមជ្ឈការនៅប្រទេសកម្ពុជា និងយល់ដឹងពីបញ្ហាដែលបានជួបប្រទះ ដំណោះស្រាយ ការទទួលបានលទ្ធផលក្នុងការធ្វើកំណែទម្រង់នោះផងដែរ។ ហើយក៏ទុកជាឯកសារសម្រាប់ឱ្យ និស្សិត ប្រជាពលរដ្ឋ និងមន្ត្រីរាជការទាំងអស់បានយល់ និងដឹងអំពីសកម្មភាពប្រព្រឹត្តយ៉ាងណា ក្នុងការធ្វើកំណែទម្រង់នេះ ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

វិធីសាស្ត្រក្នុងការស្រាវជ្រាវប្រធានបទមួយនេះ គឺមានលក្ខណៈបែបវិទ្យាសាស្ត្រដោយធ្វើការប្រមូលព័ត៌មាន យកមកចងក្រងជាសារណានេះបានឱ្យល្អ គឺធ្វើសកម្មភាពស្រាវជ្រាវដូចជា ៖

- នៅក្នុងបណ្ណាល័យ
- ដកស្រង់ចេញពីសៀវភៅដែលពាក់ព័ន្ធនិងប្រធានបទ
- ដកស្រង់ចេញពីប្រសាសន៍របស់សាស្ត្រាចារ្យ
- ដកស្រង់ពីរបាយការណ៍នៅតាមបណ្ដាញសង្គមនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីងាយស្រួលក្នុងការស្វែងយល់អំពីប្រធានបទខាងលើ យើងបានរៀបចំនូវប្លង់ស្រាវជ្រាវដែលឆ្លុះបញ្ចាំងចំពោះប្រធានបទ និងចំណោទបញ្ហាខាងលើ ដែលរួមមាន សេចក្តីផ្តើម ខ្លឹមសារមាន ជំពូក សេចក្តីសន្និដ្ឋាន អនុសាសន៍ ឯកសារយោង និងឧបសម្ព័ន្ធ ដែលមានដូចជាៈ

សេចក្តីផ្តើមៈ បានលើកឡើងពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវនិងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

ជំពូកទី១ៈ ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលលើកឡើងអំពីអត្ថន័យ គុណសម្បត្តិ និងគុណវិបត្តនៃវិមជ្ឈការ និងវិសហមជ្ឈការ។ ជាពិសេសនោះ ក៏មានការបង្ហាញអំពីការធ្វើប្រតិភូអំណាច និងការប្រតិភូកម្មហត្ថលេខាទៅកាន់អ្នកដែលមានឋានន្តរស័ក្តិក្រោមខ្លួន។ ដូចគ្នានោះដែរ នៅក្នុងជំពូកនេះក៏បាននិយាយអំពីគោលដៅ និងគោលបំណងក្នុងការអនុវត្តគោលនយោបាយវិមជ្ឈការ និងវិសហ-មជ្ឈការផងដែរ។

ជំពូកទី២ៈ ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ លើកឡើងអំពីរចនាសម្ព័ន្ធ និងការអនុវត្តកំណែទម្រង់នៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ជាងនេះទៅទៀតនៅក្នុងចំណុចនេះក៏បង្ហាញពីយុទ្ធសាស្ត្រ និងច្បាប់នានាផងដែរ។

ជំពូកទី៣ៈ លទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ។

# ជំពូកទី១

# ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

# ជំពូកទី១
# ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

## ១.១ អត្ថន័យនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ពាក្យ " កំណែទម្រង់ " មានន័យថាជាការកែប្រែអ្វីដែលខ្វះចន្លោះ ដែលកាចសាហាវ ពុករលួយ ឬធ្វើអោយខូច ។ តាមន័យអក្សរសាស្ត្រ កំណែទម្រង់ បានមកពីពាក្យ កំណែ + ទម្រង់ ។ ពាក្យ កំណែ មានន័យថាសំណៅ ឬ វិញ្ញាសាដែលគេកែរតម្រូវកន្លែងដែលគេកែហើយ ។ ពាក្យទម្រង់ មានន័យថា សណ្ឋានទ្រង់ទ្រង់ទ្រាយ និងលំនាំ។[១]

សន្ធានុក្រមនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌបានកំណត់និយមន័យពាក្យ វិមជ្ឈការ និងវិសហមជ្ឈការ ដូចខាងក្រោមះ

**វិមជ្ឈការ** មានន័យថា រាជរដ្ឋាភិបាលប្រគល់ភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន (បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) ឲ្យទៅក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៅមូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។

ឧទាហរណ៍៖ រាជរដ្ឋាភិបាលបានផ្ទេរថវិកាចំនួនមួយចំនួនសម្រាប់ថវិការបស់រដ្ឋបាលស្រុកក្នុងគោលដៅនៃការអភិវឌ្ឍ។ ដូច្នេះក្រុមប្រឹក្សាស្រុកអាចយកទៅចាត់ចែងទៅតាមការចាំបាច់ ក្នុងប្រយោជន៍រួម។

**វិសហមជ្ឈការ** មានន័យថារាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធិអំណាច និងធនធាន (បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) ទៅឱ្យអង្គភាពក្រោមបង្គាប់ ឬទៅឱ្យក្រុមប្រឹក្សាប្រភេទណាមួយដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននោះ។ មានន័យថាជាបច្ចេកទេសរដ្ឋបាលមួយ ដែលអាជ្ញាធររដ្ឋបាលកណ្តាលរំលែកអំណាច ឬកិច្ចការមួយចំនួនអោយទៅ រដ្ឋបាលមូលដ្ឋាន ធ្វើការសម្រេចដោយខ្លួនឯងផ្ទាល់។

**ប្រតិភូកម្មមុខងារ៖** គឺជាការផ្ទេរនូវមុខងារ ការទទួលខុសត្រូវអំណាច និងឆន្ទានុសិទ្ធិ ដើម្បីគ្រប់គ្រង និងអនុវត្តមុខងារក្នុងនាមអាជ្ញាធរដែលធ្វើប្រតិភូកម្ម ដោយផ្អែកតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។ អាជ្ញាធរដែលបានធ្វើប្រតិភូកម្មនៅតែរក្សាភាពជាម្ចាស់លើកិច្ចការដែលបានធ្វើប្រតិភូកម្ម។[២]

---

[១] វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជជួន ណាត ភាគ១ ភាគ២

[២] សន្ធានុក្រម ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨

ឧទាហរណ៍៖ ក្រសួងមហាផ្ទៃ ធ្វើប្រតិភូកម្ម មុខងារធ្វើសេចក្តីចម្លងអត្រានុកូលដ្ឋានទៅឱ្យក្រុមប្រឹក្សាស្រុក ហើយអភិបាលស្រុកត្រូវប្រគល់ឱ្យអនុវត្តការងារនេះ ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ ក្នុងការធ្វើប្រតិភូកម្មមុខងារនេះ ក្រសួងមហាផ្ទៃនឹងផ្តល់នូវធនធាន និងការបណ្តុះបណ្តាលសមត្ថភាព ដល់អភិបាលស្រុក និងមន្ត្រីរក្សាសៀវភៅអត្រានុកូដ្ឋាន។ អភិបាលស្រុក និងមន្ត្រីរក្សាសៀវភៅអត្រានុកូលដ្ឋានស្រុក អនុវត្តការចម្លងសំបុត្រអត្រានុកូលដ្ឋានជូនប្រជាពលរដ្ឋក្នុងស្រុករបស់ខ្លួន តាមការណែនាំពីក្រសួងមហាផ្ទៃ និងក្នុងនាមក្រសួងមហាផ្ទៃ។

### ១.១.១ ការធ្វើប្រតិកម្មអំណាច

អ្នកធ្វើប្រតិភូកម្មត្រូវគេហៅថា ប្រតិភូនាយក ចំណែកអ្នកទទួលប្រតិភូកម្មហៅថា ប្រតិភូ។ ក្នុងការធ្វើប្រតិភូកម្មអំណាចប្រតិភូកម្មមានសិទ្ធិសម្រេចជំនួស និងក្នុងនាមអាជ្ញាធរអំណាចកណ្តាល តាមរយៈលិខិតប្រតិភូកម្ម ជាលាយលក្ខណ៍អក្សរដែលមានលក្ខណៈច្បាស់លាស់។ លិខិតប្រតិភូកម្មនេះ ត្រូវធ្វើពីអាជ្ញាធរថ្នាក់លើទៅថ្នាក់ក្រោម ដោយមិនចំពោះបុគ្គលណាមួយឡើយ គឺបែងចែកអំណាចពីអាជ្ញាធរមួយទៅអាជ្ញាធរមួយទៀត ពុំមែនជារូបវន្តបុគ្គលទេ។ ការធ្វើប្រតិភូកម្ម មិនមានលក្ខណៈពេញលេញឡើយ គឺមានន័យថា មិនមែនប្រតិភូនាយកប្រគល់អំណាចទាំងស្រុងទៅប្រតិភូឡើយ។ ករណីប្រតិភូទទួលរងនូវការផ្លាស់ប្តូរ គឺការធ្វើប្រតិភូកម្មនោះមិនត្រូវបានបញ្ចប់ទេ បើអាចបញ្ចប់បានលុះត្រាតែមានលិខិតណាមួយផ្សេងទៀតមករំសាយលិខិតបែងចែកអំណាច។ ការធ្វើប្រតិភូកម្មអំណាច គឺមានការផ្ទេរអំណាចមួយយ៉ាងពិតប្រាកដ។ ប្រតិភូនាយកដែលបានធ្វើប្រតិកម្មអំណាចឲ្យមកប្រតិភូ គ្មានសិទ្ធិសម្រេចណាមួយទាក់ទងនឹងប្រភេទអំណាចដែលបានធ្វើប្រតិភូកម្ម។ រាល់សេចក្តីសម្រេចដែលចេញដោយអ្នកធ្វើប្រតិភូកម្មអំណាច គឺមានតម្លៃគតិយុត្តស្មើនឹងឋានៈរបស់ប្រតិភូនោះ។

### ១.១.២ ការធ្វើប្រតិកម្មកម្មហត្ថលេខា

ការធ្វើប្រតិភូកម្មហត្ថលេខា គឺជាវិធីមួយដែលអាជ្ញាធររដ្ឋបាលមួយប្រគល់ឲ្យ សហការីរបស់ខ្លួននូវការចុះហត្ថលេខាលើសេចក្តីសម្រេចមួយចំនួនជំនួសខ្លួន។ ការធ្វើប្រតិភូកម្មហត្ថលេខា មិនមែនជាការផ្ទេរអំណាចមួយពិតប្រាកដទេ គឺគ្រាន់តែជាការសម្រួលស្ថានការណ៍រដ្ឋបាលមួយប៉ុណ្ណោះ។ វាជាការធ្វើប្រតិភូកម្មពីបុគ្គលមួយទៀត បើសិនជាអ្នកទទួលប្រតិភូកម្មនោះផ្លាស់ចេញ ការធ្វើប្រតិភូកម្មនោះនឹងរលាយទៅវិញ។ ការធ្វើប្រតិភូកម្មនេះ គឺចំពោះតែហត្ថលេខាតែប៉ុណ្ណោះ ដោយមិនប៉ះពាល់ទៅលើការបែងចែកសមត្ថកិច្ចឡើយ។ ប្រតិភូនាយក មានសិទ្ធិសម្រេចចិត្តសារជាថ្មីគ្រប់ពេលវេលាចំពោះសេចក្តីសម្រេចដែលត្រូវចុះហត្ថលេខាដោយប្រតិភូ។ សេចក្តីសម្រេចដែលចុះហត្ថលេខាហើយមានតម្លៃគតិយុត្តស្មើនឹងសេចក្តីសម្រេចរបស់ប្រតិភូនាយក។

## ១.២ គុណសម្បត្តិ និងគុណវិបត្តិ

### ១.២.១ វិមជ្ឈការ

➢ គុណសម្បត្តិ

- ចំណាយពេលវេលាតិចក្នុងការទទួលសេវានាំអោយមានអភិវឌ្ឍន៍ ហើយប្រជាពលរដ្ឋមានភាពងាយស្រួលក្នុងការរស់នៅ
- ស្វ័យភាពការងារនាំអោយមានកម្លាំងចិត្ត ជាគ្រឹះនៃប្រជាធិបតេយ្យតាមមូលដ្ឋាន មានលិទ្ធិប្រជាធិបតេយ្យស៊ីជម្រៅ ព្រោះមានការចូលពីប្រជាពលរដ្ឋក្នុងការសម្រេចនូវអ្វីៗដែលប្រជាពលរដ្ឋក្នុងការសម្រេចនូវអ្វីៗដែលជាប្រយោជន៍វាស្រ្ត
- មានការចូលរួមពីប្រជាពលរដ្ឋ ក្នុងការធ្វើសេចក្តីសម្រេចនានា ដែលទាក់ទងនឹងផលប្រយោជន៍របស់ប្រជាជន៍របស់ប្រជាពលរដ្ឋនៅនឹងកន្លែង
- នាំឲ្យមានការអភិវឌ្ឍន៍រីកចម្រើននៅមូលដ្ឋាន លើកកម្ពស់ជីវភាពរបស់រដ្ឋកាន់តែប្រសើរឡើង
- នាំឲ្យមានរបៀបគ្រប់គ្រងរដ្ឋបាល ដែលពលរដ្ឋខ្លួនឯងស្គាល់ច្បាស់ និងងាយទទួលបាននូវសេវាសាធារណៈ។

➢ គុណវិបត្តិ

- អាចបំបែកការរួបរួមរវាងសមូហភាព និងសមូហភាព
- ធ្វើអោយអាជ្ញាធរកណ្តាលមានការទន់ខ្សោយ
- ការអភិវឌ្ឍន៍អាចតាមរបៀបអាណាធិបតេយ្យព្រោះ ការអភិវឌ្ឍន៍មានការ ប្រកួតប្រជែងនាំឲ្យមានការប៉ះពាល់ ដល់សមូហភាពរៀងៗខ្លួន
- ប្រព័ន្ធមជ្ឈការគ្មានអំណាច ឋានានុក្រមទេ ព្រោះអាជ្ញាធរនីមួយៗ មានសិទ្ធិសម្រេចរៀងៗខ្លួនតាមច្បាប់កំណត់
- នាំឲ្យមានការសម្រេចនូវផលប្រយោជន៍ពលរដ្ឋ ទៅតាមទីកន្លែងនីមួយៗមិនស្មើគ្នា ពីកន្លែងមួយទៅកន្លែងមួយ ក្នុងរឿងដូចគ្នា
- នាំឲ្យមានការអភិឌ្ឍន៍របៀប អនាធិបតេយ្យ ទៅតាមទីតំបន់ ជាបង្កឲ្យបញ្ហាផែនការរបស់រដ្ឋ ។

**ចរិកលក្ខណៈ** ៖ ក្នុងការគ្រប់គ្រងបច្ចេកទេសនេះ គឺគ្រប់គ្រងទៅតាមឋានានុក្រមរដ្ឋបាល រដ្ឋបាលកណ្តាលបានផ្តល់សេចក្តីសម្រេចទៅតាមឋានានុក្រមរៀងៗខ្លួន។ ប្រព័ន្ធការងារនីមួយៗត្រូវបានតែងតាំងដោយរដ្ឋបាលកណ្តាល ដោយគ្មានការបោះឆ្នោតណាមួយ ពោលគឺអាជ្ញាធរមូលដ្ឋានមានសិទ្ធិធ្វើការសម្រេច

ចិត្តដោយផ្អែកលើភាពសប្បុរសរបស់អាជ្ញាធររដ្ឋបាលកណ្តាល។ អាជ្ញាធរមូលដ្ឋានមិនមានថវិកាផ្ទាល់ខ្លួន ប្រើប្រាស់ថវិកាជាតិ និងគ្មានសិទ្ធិជ្រើសរើសបុគ្គលិក។

ចរិកលក្ខណៈទោះបីទម្រង់នៃការរៀបចំនេះ មានប្រគល់ឲ្យសមូហភាពដែនដីនូវសិទ្ធិអំណាច ក្នុងការសម្រេចប្រកបដោយស្វ័យភាពក៏ដោយក៏នៅមានកិច្ចការមួយចំនួន អាជ្ញាធរកណ្តាលឱបក្រសោបតែម្នាក់ឯងនោះគឺ៖

- កិច្ចការធ្វើច្បាប់
- កិច្ចការការទូត
- កិច្ចការអគ្រានុកូលដ្ឋាន
- ធនធានធម្មជាតិ

វាជាកិច្ចការផ្តាច់មុខរបស់រដ្ឋ។ រដ្ឋបាលកណ្តាលផ្តល់សមូហភាពដែនដីអោយទៅ រដ្ឋបាលមូលដ្ឋានភាគច្រើន គឺផ្អែកសេដ្ឋកិច្ច វប្បធម៌ និងការងារអភិវឌ្ឍន៍ ។

### ១.២.២ ទិសហមជ្ឈការ

➢ គុណសម្បត្តិ

- កាត់បន្ថយការប្រើប្រាស់អំណាចហួសហេតុរបស់អាជ្ញាធរកណ្តាល
- អាជ្ញាធរមូលដ្ឋានសម្រេចបញ្ហានៅនឹងកន្លែង
- ការងារឆាប់រហ័សចំណេញពេលវេលា និងថវិកា

➢ គុណវិបត្តិ

- ខ្វះលទ្ធិប្រជាធិបតេយ្យ ( រាល់ការសម្រេចស្ថិតនៅលើអំណាចកណ្តាល )
- ធ្វើអោយរដ្ឋបាលកណ្តាល ក្តាប់មិនបានល្អនូវអំណាចរបស់ខ្លួន ការងារខ្លះពិនិត្យតាមតែរបាយការណ៍របស់ថ្នាក់ក្រោមដែលបានផ្តល់អោយ ដោយពុំបានជ្រាបពីភាពពិតប្រាកដនៅឯមូលដ្ឋាន
- ភ្នាក់ងាររាជការដែលតំណាងអោយរដ្ឋ មិនងាយមានទស្សនៈវិស័យក្នុងការអភិវឌ្ឍឱ្យលើសអ្វីដែលថ្នាក់លើប្រគល់ជូនឡើង គឺត្រូវធ្វើតាមបញ្ជាពីថ្នាក់លើប្រគល់ឱ្យតែប៉ុណ្ណោះ
- នាំអោយមានការអនុវត្តពុំចំទិសដៅនឹងតំរូវការរបស់ពលរដ្ឋនូវតំបន់នីមួយៗ។

## ១.៣ គោលដៅ

ទី១ ៖ ការពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន

ទី២ ៖ ការជំរុញកិច្ចអភិវឌ្ឍន៍មូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កលក្ខណៈ

ឱ្យប្រជាពលរដ្ឋចូលរួមក្នុងការចាំបាច់នានានៅមូលដ្ឋាន សំដៅលើកកម្ពស់ភាពជាម្ចាស់របស់សហគមន៍មូលដ្ឋាន។

ទី៣ ៖ លើកកម្ពស់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។

## ១.៤ គោលបំណង

- ធានាឲ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពទូលំទូលាយ សំដៅពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចនៅមូលដ្ឋាន
- ធានាឲ្យប្រជាពលរដ្ឋគ្រប់រូបមានឱកាសស្មើគ្នា ក្នុងការចូលរួមរៀបចំ និង អនុវត្តផែនការអភិវឌ្ឍន៍មូលដ្ឋានរបស់ខ្លួន
- បង្កើតនូវបរិយាកាសប្រកបដោយប្រសិទ្ធិភាព សម្រាប់គ្រប់គ្រងធនធានធម្មជាតិ និងការផ្តល់សេវាសាធារណៈប្រកបដោយគុណភាព
- ការចូលរួមរបស់ប្រជាពលរដ្ឋ សេចក្តីសម្រេច
- គណនេយ្យភាពនៃសេវាសាធារណៈ ត្រូវឲ្យពលរដ្ឋពិនិត្យកិច្ចការរដ្ឋបាល និងហិរញ្ញវត្ថុ
- ប្រសិទ្ធភាព លើកកម្ពស់គុណភាពសេវាសាធារណៈ
- ការផ្តោតលើការកាត់បន្ថយភាពក្រីក្រ ប្រើប្រាស់ធនធាន។

# ជំពូកទី២

# ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

# ជំពូកទី២

# ដំណើរការនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## ២.១ រចនាសម្ព័ន្ធ

ប្រព័ន្ធរដ្ឋបាលនៅប្រទេសកម្ពុជាចែកចេញជា ថ្នាក់កណ្តាលឬរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់មូលដ្ឋានឬថ្នាក់ក្រោមជាតិ។ រដ្ឋបាលថ្នាក់ជាតិ មានគណរដ្ឋមន្ត្រី និងស្ថាប័នរដ្ឋ។ នៅក្នុងគណរដ្ឋមន្ត្រី មានអង្គភាពចំណុះ ចំណែកឯរដ្ឋបាលថ្នាក់ក្រោមជាតិ មានរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។ នៅក្នុងប្រទេសកម្ពុជាមានរាជធានីតែមួយគត់ គឺរាជធានីភ្នំពេញ។ រាជធានីភ្នំពេញ ចែកជាខណ្ឌ ហើយខណ្ឌចែកជាសង្កាត់។[៣] ចំពោះខេត្តត្រូវបានចែកជាពីរទៀតគឺ ក្រុង និងស្រុក ហើយក្រុងចែកជា សង្កាត់ ។ ចំណែកឯ ស្រុកត្រូវបានចែកជា ឃុំ និងសង្កាត់។[៤]

ចំនួនសមាជិកក្រុមបឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃប្រាំពីរ (២៧) រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីដប់ប្រាំ (១៥) រូប ដល់ម្ភៃប្រាំពីរ (២៧) រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីដប់មួយ (១១) រូប ដល់ម្ភៃមួយ (២១) រូប
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីដប់មួយ (១១) រូប ដល់ម្ភៃមួយ (២១) រូប។

## ២.២. ក្របខណ្ឌគោលនយោបាយ និងច្បាប់

គោលនយោបាយ និងច្បាប់សំខាន់ៗសម្រាប់គាំទ្រដល់ដំណើរការនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា រួមមាន៖

- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤
- ក្របខណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[៣] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា៤

[៤] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា៥

- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ទន្ទឹមនឹងការដាក់ចេញក្របខ័ណ្ឌគោលនយោបាយ និងក្របខណ្ឌច្បាប់ខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានរៀបចំនូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលការអនុវត្តកម្មវិធីជាតិនេះ ត្រូវបានចែកចេញជាបីដំណាក់កាល ទី១ (ផអ៣ទី១) ដែលមានរយៈពេល០៣ឆ្នាំ+០១ឆ្នាំ (២០១១-២០១៤ ) និងផែនការអនុវត្តរយៈពេល៣ឆ្នាំដំណាក់កាលទី២ ( ផអ៣ទី២ ) ( ២០១៥-២០១៧ ) បានបញ្ចប់។ បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តផែនការអនុវត្តរយៈពេល៣ឆ្នាំ ( ២០១៨-២០២០ ) ដោយផ្តោតការយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាព និងលទ្ធភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ខាងក្រោមនេះ គឺជាខ្សែពេលវេលានៃដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។




**ផអ៣ទី១៖** ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី១ (២០១១–២០១៤)

**ផអ៣ទី២៖** ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី២ (២០១៥–២០១៧)

**ផអ៣ទី៣៖** ផែនការអនុវត្តរយៈពេលបីឆ្នាំដំណាក់កាលទី៣ (២០១៨–២០២០)

### ២.២.១ យុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤

ក្នុងការអនុវត្តដំណាក់កាលយុទ្ធសាស្រ្តចតុកោណទាំង៣ដំណាក់កាលកន្លងមករាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាមូលដ្ឋាន ក្នុងការធ្វើទំនើបកម្មប្រព័ន្ធអភិបាលកិច្ច តាមរយៈការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការកែទម្រង់កងកម្លាំងប្រដាប់អាវុធ។ គោលដៅនៃយុទ្ធសាស្រ្តដំណាក់កាលទី៤ គឺការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន សមធម៌ និងយុត្តិធម៌ តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងរដ្ឋបាល ក្នុងការដឹកនាំគ្រប់គ្រង និងចាត់ចែងកិច្ចការរបស់ប្រទេស ជាពិសេសការធានានិរន្តរភាពនៃតួនាទី និងដំណើរការរដ្ឋបាលសាធារណៈដោយយកចិត្តទុកដាក់ទៅលើអត្ថប្រយោជន៍ប្រជាជនជាស្នូល ( People-Centric ) និងការកសាងជាតិ (Nation-state Building ) ។[៦]

**បរិយាប័ន្នៈ** សំដៅដល់ការលើកកម្ពស់ស្ថានភាពរបស់បុគ្គល និងក្រុមនានាក្នុងការចូលរួម និងការទទួលផលពីសកម្មភាពនានា របស់សង្គមដោយមិនរើសអើង។[៧]

ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ ទី៤ ទី៥ និងទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្រ្តចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ ដោយផ្តោតការយកចិត្តដាក់លើកំណែទម្រង់បួនរួមមានៈ

- កំណែទម្រង់រដ្ឋបាលសាធារណៈ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ
- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ។

កំណែទម្រង់ទាំងបួននេះត្រូវបានពង្រឹងពង្រីក និងយកចិត្តទុកដាក់អនុវត្តកាន់តែស៊ីជម្រៅពីដំណាក់កាលមួយទៅដំណាក់កាលមួយ។

### ២.២.២ ក្របខណ្ឌយុទ្ធសាស្រ្តចតុកោណស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

នៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យមានក្របខ័ណ្ឌយុទ្ធសាស្រ្តពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងគោលបំណងកំណត់អំពីៈ

[៦] យុទ្ធសាស្រ្តចតុកោណ ទំព័រទី១២

[៧] គេហទំព័រ ស្វែងយល់ពាក្យបច្ចេកទេស

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធ
- គ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ រៀបចំឡើងដោយឈរលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់តាមរយៈការដាក់ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ២០០១។ ផ្អែកតាមក្របខណ្ឌជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើនៅក្នុងឆ្នាំ២០០៨។

ក្នុងការដាក់ឱ្យដំណើរការនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមស្មារតីនៃច្បាប់រៀបចំអង្គការ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធបានដាក់ចេញនូវព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀតជាច្រើន ដើម្បីធានាឱ្យប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានអាចដំណើរការទៅបានប្រកបដោយភាពរលូន មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

### ២.២.៣ ច្បាប់រៀបចំអង្គការ

ច្បាប់រៀបចំអង្គការសំដៅលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ច្បាប់ទាំងនេះមានគោលបំណងកំណត់អំពីការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រួមទាំងការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។

## ២.៣ កំណែទម្រង់ថ្នាក់ជាតិ

ប្រទេសកម្ពុជា បានទទួលប្រព័ន្ធច្បាប់ នយោបាយ និងរដ្ឋបាលសាធារណៈមួយចំនួនពីប្រទេស

បារាំង។ ព្រះរាជាណាចក្រកម្ពុជា គឺជារដ្ឋមិនអាចបំបែកបាន។ យោងតាមរដ្ឋធម្មនុញ្ញ គោលការណ៍រាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងប្រជាធិបតេយ្យសេរីពហុបក្ស កំណត់ឱ្យប្រព័ន្ធរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ ខណៈដែលព្រះមហាក្សត្រទ្រង់គ្រងសម្បត្តិ ប៉ុន្តែមិនកាន់អំណាច សិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋខ្មែរ ត្រូវបានទទួលស្គាល់ និងការពារ ហើយគណបក្សនយោបាយត្រូវបានជម្រុញឱ្យចូលរួមនៅក្នុងការបោះឆ្នោតកាន់តែច្រើន។

គណៈរដ្ឋមន្ត្រី គឺជារាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ( តំណាងឱ្យអង្គនីតិប្រតិបត្តិ ) ។ ស្ថាប័នកំពូលនៃអំណាចនីតិប្រតិបត្តិមួយនេះ មានសមាសភាព នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ សមាជិករដ្ឋាភិបាលភាគច្រើន គឺជាប្រធានក្រសួង និងស្ថាប័នជាតិនានា។ សមាជិករាជរដ្ឋាភិបាលទាំងនេះ គឺជាអ្នកទទួលខុសត្រូវលើការអនុវត្តច្បាប់ និងបទបញ្ជា ព្រមទាំងគោលនយោបាយដែលសភាបានអនុម័ត និងព្រះមហាក្សត្រប្រកាសឱ្យប្រើឬដាក់ចេញដោយរាជរដ្ឋាភិបាល។

ប្រជាធិបតេយ្យសេរីពហុបក្ស គឺជាគោលការណ៍យកមកប្រតិបត្តិសម្រាប់ប្រព័ន្ធនយោបាយនៃប្រទេសនេះ។ ជាមួយនឹងការចូលរួមការបោះឆ្នោតដោយគណបក្សនយោបាយជាច្រើន ប្រជាពលរដ្ឋខ្មែរបោះឆ្នោតជ្រើសតាំងតំណាងរបស់ពួកគេ ទោះដោយផ្ទាល់ក្ដីឬដោយប្រយោលក្ដី។ ជាការពិតណាស់ ខណៈពេលដែលប្រព័ន្ធសភានៃប្រទេសនេះដើរតាមសភានិយម មានតែសមាជិករដ្ឋសភាប៉ុណ្ណោះដែលត្រូវបានបោះឆ្នោតជ្រើសតាំងដោយផ្ទាល់ពីប្រជាពលរដ្ឋ ហើយសមាជិកព្រឹទ្ធសភាត្រូវបានបោះឆ្នោតជ្រើសតាំងដោយមិនផ្ទាល់។ សភាទាំងពីរថ្នាក់នេះបង្កើតបានជាសភានៃប្រទេសកម្ពុជា។

ចាប់តាំងពីការស្ដារឡើងវិញនូវរបបរាជានិយមជាលើកទី២មក មានការបោះឆ្នោតជាសកល និងដោយផ្ទាល់ចំនួន៦លើករួចមកហើយ។ នេះមានន័យថា រដ្ឋសភា និងរដ្ឋាភិបាលនៃប្រទេសកម្ពុជា គឺស្ថិតនៅអាណត្តិទី៦របស់ខ្លួន។ ការបោះឆ្នោតជាតិជ្រើសតាំងសមាជិករដ្ឋសភា ត្រូវបានរៀបចំឡើងចំនួនប្រាំមួយដងរួចមកហើយនៅឆ្នាំ ១៩៩៣, ឆ្នាំ១៩៩៨, ឆ្នាំ២០០៣, ឆ្នាំ២០០៨, ឆ្នាំ២០១៣ និងឆ្នាំ២០១៨។

ព្រឹទ្ធសភានីតិកាលទី១ ( ១៩៩៩-២០០៦ ) កើតឡើងដោយការតែងតាំង មានសមាជិកចំនួន ៦១រូប ក្នុងនេះមានគណបក្សប្រជាជនកម្ពុជា ៣៣រូប ហ៊្វុនស៊ិនប៉ិច ២១រូប និងគណបក្សសមរង្ស៊ី ៧រូប ( ការបែងចែកអាសនៈទៅតាមចំនួនកូតានៃគណបក្សមានអាសនៈក្នុងរដ្ឋសភានីតិកាលទី២ ) សម្រាប់ រយៈពេល ៥ឆ្នាំ ។

ព្រឹទ្ធសភានីតិកាលទី១បានបន្តនីតិកាលរបស់ខ្លួនចំនួន២ដង(ម្ដង១ឆ្នាំ)៖

- លើកទី១ ព្រះរាជសារចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៤ របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី បានបន្តនីតិវិធីបោះឆ្នោតសម្ងាត់ក្នុងសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី១ នាថ្ងៃទី ១៣ ខែកុម្ភៈ ឆ្នាំ

២០០៤ ដោយមានសំឡេងគាំទ្រចំនួន ៤៩សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូល (គិតចាប់ពីថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៤ ដល់ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥)។

- លើកទី២ ព្រះរាជសារចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០០៥ របស់ព្រះមហាក្សត្រ នរោត្តម សីហមុនី និងបានបន្តនីតិវិធីបោះឆ្នោតសម្ងាត់ក្នុងសម័យប្រជុំលើកទី៩ ព្រឹទ្ធសភា នីតិកាលទី១ នាថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០០៥ ដោយមានសំឡេងគាំទ្រចំនួន ៤៨ សំឡេង នៃចំនួនសមាជិកព្រឹទ្ធសភាទាំងមូលគិតចាប់ពី ថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៥ ដល់ព្រឹទ្ធសភានីតិកាលទី២ ចូលកាន់តំណែង នាថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០០៦។ ក្នុងនីតិកាលទី១នេះ ព្រឹទ្ធសភាបានផ្តួចផ្តើមគំនិតស្នើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក ព្រឹទ្ធសភា ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំលើកទី២ នីតិកាលទី៣ ហើយព្រឹទ្ធសភាបានពិនិត្យ និងឲ្យយោបល់យល់ស្របលើទម្រង់ និងគតិច្បាប់នេះទាំងស្រុង នៅថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំលើកទី៩ នីតិកាលទី១។ បន្ទាប់មក ក្រុមប្រឹក្សាធម្មនុញ្ញបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ តាមសេចក្តីសម្រេចលេខ ០៧០.២០០៥ កបធ/០០២/ច ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥ ។

ព្រឹទ្ធសភានីតិកាលទី២ (២០០៦-២០១២) កើតឡើងដោយការបោះឆ្នោតអសកល នាថ្ងៃអាទិត្យ ទី២២ ខែមករា ឆ្នាំ២០០៦ សម្រាប់រយៈពេល៦ឆ្នាំ ។ នីតិកាលទី២ សមាជិកព្រឹទ្ធសភាមានចំនួន ៦១រូប ដូចនីតិកាលទី១( ០២រូបចាត់តាំងដោយព្រះមហាក្សត្រ ០២រូបជ្រើសតាំងដោយរដ្ឋសភា និង ៥៧រូបជ្រើសតាំងដោយការបោះឆ្នោត ) ក្នុងនោះមានសមាជិកា ០៩រូប ។ ក្នុង៥៧រូបដែលជ្រើសតាំងដោយការបោះឆ្នោតមាន ៤៥រូបមកពីគណបក្សប្រជាជនកម្ពុជា ១០រូបមកពីគណបក្សហ្វ៊ុនស៊ិនប៉ិច និង ០២រូបមកពីគណបក្សសមរង្ស៊ី ។

ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៣ បានប្រព្រឹត្តទៅនាថ្ងៃ អាទិត្យ ទី ២៩ ខែ មករា ឆ្នាំ ២០១២ ។សម្រាប់នីតិកាលទី៣នេះ ចំនួនសមាជិកព្រឹទ្ធសភាមានចំនួន ៦១រូប ដូច នីតិកាលទី១ និងនីតិកាលទី២ ក្នុងនោះមានសមាជិកាចំនួន ១០រូប ( មកពីគណបក្សប្រជាជនកម្ពុជា ០៦រូប សមរង្ស៊ី ០៣ រូប និងជ្រើសតាំងដោយរដ្ឋសភា ០១រូប ) ។

រដ្ឋបាលដែនដីនៃប្រទេស ត្រូវបានបែងចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់។[៩] ការរៀបចំ និងការប្រព្រឹត្តទៅនៃរដ្ឋបាលខេត្ត និងដែនដី នៅតែស្ថិតក្រោមការត្រួតពិនិត្យ ដោយរដ្ឋបាលថ្នាក់ជាតិ តាមរយៈក្របខណ្ឌច្បាប់ឬក្របខណ្ឌស្ថាប័ន។ ចំណែកឯភូមិ មិនត្រូវបានទទួលស្គាល់ ជាផ្នែកនៃរដ្ឋបាលដែនដីនៃប្រទេសកម្ពុជាទេ។

[៩] រដ្ឋធម្មនុញ្ញ មាត្រា១៤៦ថ្មី។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ត្រូវបានធ្វើវិសោធនកម្មចុងក្រោយបំផុតនៅឆ្នាំ ២០១៨

គ្រប់បទដ្ឋានក្រោមច្បាប់ដែលត្រូវបានចេញដោយរដ្ឋាភិបាល និងក្រសួង ស្ថាប័ន រដ្ឋាភិបាល តែងមានឋានានុក្រមខ្ពស់ជាងបទដ្ឋានចេញដោយរដ្ឋបាលដែនដី។ ដូចគ្នានេះ នៅរដ្ឋបាលមូលដ្ឋាន ក្រសួងនិងស្ថាប័នរដ្ឋាភិបាល មានរចនាសម្ព័ន្ធគ្រប់គ្រងរបស់ខ្លួននៅតាមបណ្តាខេត្តជាមន្ទី និងបណ្តាក្រុងឬស្រុក ជាការិយាល័យ។ ហេតុដូច្នេះ រដ្ឋបាលដែនដីនៅគ្រប់កម្រិត អនុវត្តសិទ្ធិអំណាចក្នុងនាមរដ្ឋបាលថ្នាក់ជាតិ។

## ២.៤ កំណែទម្រង់ថ្នាក់ក្រោមជាតិ

រដ្ឋបាលថ្នាក់ក្រោមជាតិសំដៅទៅលើ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់។

- រាជធានី គឺជារដ្ឋបាលរាជធានីដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជធានី
- ខេត្ត គឺជារដ្ឋបាលខេត្តដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត
- ក្រុង គឺជារដ្ឋបាលក្រុងដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាក្រុង
- ស្រុក គឺជារដ្ឋបាលស្រុកដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាស្រុក
- ខណ្ឌ គឺជារដ្ឋបាលខណ្ឌដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខណ្ឌ
- ឃុំ គឺជារដ្ឋបាលឃុំដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ
- សង្កាត់ គឺជារដ្ឋបាលសង្កាត់ដែលស្ថិតក្រោមសមត្ថកិច្ចរបស់ក្រុមប្រឹក្សាសង្កាត់។

### ២.៤.១ ការអនុវត្តន៍ភារកិច្ចរបស់រដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

#### ២.៤.១.១ ក្រុមប្រឹក្សារាជធានី-ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានី ខេត្ត ក្រុង ខណ្ឌ ត្រូវមានក្រុមប្រឹក្សារបស់ខ្លួន ដែលត្រូវបានជ្រើសរើសឡើង តាមការបោះឆ្នោតអសកល ស្របតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលហៅកាត់ថា " ក្រុមប្រឹក្សា " ។ ក្រុមប្រឹក្សាមានអាណត្តិប្រាំ (០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់ដំណែង ។ អាណត្តិរបស់ក្រុមប្រឹក្សាត្រូវគិតចាប់ពីថ្ងៃបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា និងផុតកំណត់នៅថ្ងៃបោះឆ្នោតបន្តបន្ទាប់ ។

ក្រុមប្រឹក្សានីមួយៗ ត្រូវមានប្រធានម្នាក់ ។ ប្រធានក្រុមប្រឹក្សា គឺជាបេក្ខជនដែលស្ថិតនៅលំដាប់លេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានអាសនៈច្រើនជាងគេ នៅក្នុងក្រុមប្រឹក្សា ហើយបើក្នុងករណីដែលបញ្ជីបេក្ខជនមានអាសនៈស្មើគ្នានៅក្នុងក្រុមប្រឹក្សា ប្រធានក្រុមប្រឹក្សា ត្រូវជ្រើសយកបេក្ខជន ដែលមានលេខរៀងលើគេនៃបញ្ជីបេក្ខជនដែលមានសំឡេងឆ្នោតបានការច្រើនជាងគេ ។ ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយផ្អែកតាមកត្តាប្រជាសាស្ត្រ និងកត្តាភូមិសាស្ត្រ ដូចខាងក្រោម៖

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃមួយ ( ២១ ) រូប

- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីប្រាំបួន ( ០៩ ) រូប ដល់ម្ភៃមួយ ( ២១ ) រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីប្រាំពីរ ( ០៧ ) រូប ដល់ដប់ប្រាំ ( ១៥ ) រូប
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីប្រាំពីរ ( ០៧ ) រូប ដល់ដប់ប្រាំបួន (១៩ ) រូប។ ចំនួនជាក់ស្តែងនៃសមាជិកក្រុមប្រឹក្សានីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ (១២០ )ថ្ងៃ មុនពេលផុតកំណត់អាណត្តិរបស់ក្រុមប្រឹក្សា។ ក្នុងករណីគ្មានអនុក្រឹត្យ ចែងអំពីចំនួនសមាជិកក្រុមប្រឹក្សាអាណត្តិបន្ទាប់ទេនោះចំនួនសមាជិកសរុបរបស់ក្រុមប្រឹក្សា សម្រាប់ក្រុមប្រឹក្សានីមួយៗត្រូវយកតាមចំនួនសរុបចុងក្រោយនៃក្រុមប្រឹក្សាអាណត្តិចាស់ ។

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណៈសម្បត្តិ ដូចខាងក្រោម ៖

- មានសញ្ញាតិខ្មែរពីកំណើត
- មានអាយុយ៉ាងតិចម្ភៃប្រាំ ( ២៥ )ឆ្នាំមកដល់ថ្ងៃបោះឆ្នោត
- មានសិទ្ធិបោះឆ្នោត និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

សមាជិកក្រុមប្រឹក្សាម្នាក់ត្រូវបាត់បង់សមាជិកភាពពីក្រុមសមាជិកក្រុមប្រឹក្សាក្នុងករណីណាមួយ ដូចខាងក្រោម ៖

- សាមីខ្លួនបាត់បង់លក្ខណៈសម្បត្តិ និងលក្ខខណ្ឌសម្រាប់ឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា
- សាមីខ្លួនសុំលាឈប់ពីក្រុមប្រឹក្សា តាមការដាក់ពាក្យសុំលាឈប់ជាលាយលក្ខណ៍អក្សរទៅប្រធានក្រុមប្រឹក្សា
- សាមីខ្លួនទទួលមរណភាព
- សាមីខ្លួនមិនបានចូលរួមក្នុងកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាប់ៗគ្នា ចាប់ពី ពីរ (០២ )ដងឡើងទៅ ដោយគ្មានច្បាប់អនុញ្ញាត
- សាមីខ្លួនត្រូវបណ្តេញចេញពីសមាជិកក្រុមប្រឹក្សា អនុលោមតាមច្បាប់ នីតិវិធី ឬបទបញ្ជាផ្ទៃក្នុង ឬ ក្រមសីលធម៌របស់ក្រុមប្រឹក្សា

- សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសស្តីពីបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយ
- សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

នៅពេលដែលមានសមាជិកក្រុមប្រឹក្សាណាម្នាក់បាត់បង់សមាជិកភាពពីក្រុមប្រឹក្សា ត្រូវជ្រើសរើសបេក្ខជនលំដាប់លេខរៀងបន្ទាប់ ពីក្នុងបញ្ជីបេក្ខជនជាមួយមកជំនួសក្នុងរយៈពេលយ៉ាងយូរដប់បួន ( ១៤ )ថ្ងៃ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត " គ ជ ប " ត្រូវរៀបចំការបោះឆ្នោតឡើងវិញ។ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មិនត្រូវបានបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយប្រជាពលទេ ពោលគឺសមាជិកក្រុមប្រឹក្សា ឃុំ សង្កាត់ នៅក្នុងមុខតំណែង ដែលជាអ្នកបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។[៩] ក្នុងករណីដែលមានក្រុមប្រឹក្សាណាមួយត្រូវរំសាយ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវចាត់វិធានការដើម្បីគ្រប់គ្រងជំនួសរហូតដល់មានក្រុមប្រឹក្សាថ្មីចូលកាន់ដំណែង ។

សមាជិកក្រុមប្រឹក្សានៅក្នុងមុខតំណែង ត្រូវទទួលប្រាក់ឧបត្ថម្ភ ដែលត្រូវបើកចេញពីគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រុមប្រឹក្សានោះ ។ ប្រាក់ឧបត្ថម្ភខាងលើនេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហារផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ២.៤.១.២ តួនាទី និងភារកិច្ចក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំចាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ដែលបានប្រគល់ និង/ឬ ដែលបានធ្វើប្រតិភូកម្ម ដោយមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

**ក . ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សា**

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងតិចចំនួន១២ ដង ក្នុងមួយឆ្នាំ ទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សា ។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់។

**ខ . ការងាររៀបចំបទបញ្ជាផ្ទៃក្នុង**

ដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន ។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងតាមទម្រង់ជាដីកា និងត្រូវអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុន ២៥ថ្ងៃ ឬលើសពី៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១ ។

[៩] ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មាត្រា២៧

**គ . ការងាររៀបចំវិធានគ្រប់គ្រងផ្ទៃក្នុង**

ក្រុមប្រឹក្សានៃអាណត្តិនីមួយៗ ត្រូវរៀបចំ និងអនុម័តដីកាស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុង ដើម្បីធានានូវការលើកកំម្ពស់ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ។

**ឃ . ការងារដាក់ចេញដីការ និងសេចក្តីសម្រេច**

ក្រុមប្រឹក្សាអាចដាក់ចេញដីការ ដើម្បីកំណត់ ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាព នីតិវិធី ឬកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនាធានរបស់ខ្លួន ដោយផ្អែកតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងតម្រូវការក្នុងមូលដ្ឋាន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏អាចដាក់ចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាពីរប្រភេទ គឺសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និងដោយផ្ទាល់មាត់ក្នុងអង្គប្រជុំក្រុមប្រឹក្សាដោយត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សា។

**ង . ការងាររៀចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់**

ក្រុមប្រឹក្សាត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខ្លួន ក្នុងអំឡុងពេលខែមិថុនានៃឆ្នាំនីមួយៗ ដោយត្រូវធ្វើឡើងនៅតាមឃុំ និងសង្កាត់ និងសង្កាត់នានាក្នុងក្រុង ក្នុងគោលបំណងផ្តល់ឱកាសឱ្យក្រុមប្រឹក្សាដើម្បី ៖

- ផ្តល់នូវព័ត៌មាន ក្រុមប្រឹក្សារាយការណ៍អំពីសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និងបង្ហាញពីផែនការសម្រាប់ឆ្នាំខាងមុខ
- ផ្តល់ប្រឹក្សា អ្នកចូលរួមពិភាក្សាអំពីលទ្ធផល ផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាអំពីការងារនៅក្នុងឆ្នាំកន្លងមក និងលើកជាសំណើសម្រាប់ឆ្នាំបន្ទាប់
- ជំរុញឱ្យមានការចូលរួម អ្នកចូលរួមចំណែកនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្តដែលក្នុងនោះសំណើ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានលើកយកមកពិចារណានៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា
- លើកកម្ពស់ការសហការ ក្រុមប្រឹក្សាទទួលបានព័ត៌មានប្រសើជាងមុនអំពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។ វេទិការបស់ក្រុមប្រឹក្សាជំរុញ និងលើកកម្ពស់កិច្ចសហការគ្នារវាង ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។ វេទិកានេះ ចូលរួមចំណែកក្នុងការបង្កើតនូវដំណោះស្រាយ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ។

**ច . ការងារផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

ក្រោយប្រកាសចូល ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ ( ៥ )ឆ្នាំ យ៉ាងយូរត្រឹមឆ្នាំទី២ នៃអាណត្តិរបស់ក្រុមប្រឹក្សា ។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ ( ៥ )ឆ្នាំត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមរយៈការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេង និងអ្នកពាក់ព័ន្ធនានាដោយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធិភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។

**ឆ . ការអនុវត្តមុខងារ**

ក្រុមប្រឹក្សាត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាថារាល់មុខងារដែលផ្ទេរទៅឱ្យក្រុមប្រឹក្សារួមទាំងមុខងារជាអាណត្តិទូទៅដែលក្រុមប្រឹក្សាបានសម្រេចជ្រើសរើសយកមកអនុវត្ត ត្រូវបានយកទៅអនុវត្តយ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន ។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏ត្រូវត្រួតពិនិត្យ និងផ្តល់យោបល់ការអនុវត្តមុខងារទាំងនោះ តាមរយៈការពិនិត្យ ពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដោយមានគណៈអភិបាលជាអ្នកធ្វើសេចក្តីរាយការណ៍ពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារទាំងនោះ។

**ជ . ការងារគ្រប់គ្រងបុគ្គលិក**

ក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួននៅរដ្ឋបាលក្រុង ក្រុមប្រឹក្សាត្រូវត្រួតពិនិត្យ និងអនុម័តលើការងារសំខាន់ៗមួយចំនួន ដូចខាងក្រោម ៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាល និងប្រធានការិយាល័យ ឬប្រធាន

អង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែល

– ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។

**ឈ . ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ**

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធិភាព តម្លាភាព និង គណនេយ្យភាពបំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ដោយក្នុងនោះការងារសំខាន់ៗរួមមាន ៖

– ការពិនិត្យ និងអនុម័តក្របខ័ណ្ឌចំណាយរយៈមធ្យម
– ការពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ
– តាមដានត្រួតពិនិត្យការអនុវត្តថវិកាដោយគណៈអភិបាល
– ការពិនិត្យ និងអនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
– ការពិនិត្យ និងអនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិជាដើម ។

និតិវិធីនៃការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយច្បាប់ និង លិខិតបទដ្ឋានពាក់ព័ន្ធ តាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញ វត្ថុ។[១០]

**២.៤.១.៣ សិទ្ធិអំណាចក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ក្រុម ប្រឹក្សាប្រើប្រាស់អំណាចបញ្ញត្តិរបស់ខ្លួនតាមរយៈការធ្វើដីកា និងប្រើប្រាស់អំណាចប្រតិបត្តិតាមរយៈការធ្វើ សេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ស្របតាមប្រកខណ្ឌដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋាន គតិយុត្តនានា។

ទន្ទឹមនេះ ក្រុមប្រឹក្សាអាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខដំណែង ក្នុងករណីអភិបាល អភិបាលរងនោះមានករណីណាមួយខាងក្រោម ៖

– បាត់បង់លក្ខណៈសម្បត្តិជាអភិបាល ឬអភិបាលរង
– អសមត្ថភាព
– បំពេញការងារមិនបានល្អ
– មានញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
– បោះបង់ចោលការងារ

[១០] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា៤៦ កថាខណ្ឌទី២

- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។

យោងតាមអនុក្រឹត្យស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក ក្រសួងមហាផ្ទៃមានតួនាទី ភារកិច្ច ដឹកនាំ ណែនាំ តម្រង់ទិស សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃរដ្ឋបាលស្រុកដើម្បីធានាឱ្យរដ្ឋបាលស្រុកគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងាររបស់ខ្លួនបានត្រឹមត្រូវ។

**២.៤.១.៤ កិច្ចប្រជុំការងារក្រុមប្រឹក្សារាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ**

កិច្ចប្រជុំរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានពីរប្រភេទគឺ កិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ។ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា ជាសម័យអង្គប្រជុំរបស់ក្រុមប្រឹក្សា។ រយៈពេលនៃសម័យប្រជុំនីមួយៗរបស់ក្រុមប្រឹក្សា គឺអាស្រ័យលើរបៀបវារៈនៃសម័យប្រជុំរបស់ក្រុមប្រឹក្សា។ ការប្រជុំវិសាមញ្ញ គឺត្រូវធ្វើនៅក្នុងដែនសម្ថកិច្ចរបស់ខ្លួនយ៉ាងហោចណាស់ដប់ពីរ (១២)ដង ជារៀងរាល់ឆ្នាំ ហើយមិនត្រូវបានប្រារព្ធឡើងមុនម្ភៃប្រាំ (២៥) និងលើសពីសាមសិបប្រាំ (៣៥)ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ ។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុម័តប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនសំរាប់រយៈពេលដប់ពីរ (១២)ខែ មិនឱ្យហួសពីកិច្ចប្រជុំសាមញ្ញលើកទី២ និងប្រតិទិនសម្រាប់កិច្ចប្រជុំសាមញ្ញលើកក្រោយៗទៀតក្នុងរយៈពេលដប់ពីរ ( ១២ ) ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងឱ្យបានជាក់លាក់ ដោយប្រកាសក្នុងរយៈពេលមិនឱ្យលើសពីបី ( ៣ )ថ្ងៃ បន្ទាប់ពីក្រុមប្រឹក្សាបានអនុម័ត។

អង្គប្រជុំរបស់ក្រុមប្រឹក្សាត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែក្នុងករណីចាំបាច់ដែលក្រុមប្រឹក្សាត្រូវប្រជុំជាសម្ងាត់ដូចមានចែងក្នុងប្រការ៧ នៃបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ។ ប្រធានក្រុមប្រឹក្សាជាអ្នកកោះអញ្ជើញសមាជិករបស់ខ្លួនឱ្យចូលរួមគ្រប់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា។ គ្រប់កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ត្រូវមានលិខិតអញ្ជើញ ដែលត្រូវប្រគល់ជូនគ្រប់រូបនៃក្រុមប្រឹក្សានិងពាក់ព័ន្ធនានា ក្នុងរយៈពេលបី ( ០៣ ) ថ្ងៃការងារ មុនកិច្ចប្រជុំចាប់ផ្តើម។

ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សាចំនួនមួយភាគបី (១/៣ ) នៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូលអាចស្នើសុំឱ្យមានកិច្ចប្រជុំវិសាមញ្ញបាន ។លិខិតអញ្ជើញ និងរបៀបវារៈសម្រាប់កិច្ចប្រជុំវិសាមញ្ញ ត្រូវចែកជូនដល់សមាជិកក្រុមប្រឹក្សាគ្រប់រូប ឱ្យបានយ៉ាងតិចពីរ ( ០២ ) ថ្ងៃការងារ មុនកិច្ចប្រជុំចាប់ផ្តើម។

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អាចប្រជុំជាសម្ងាត់បាន ស្របតាមសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

## ២.៤.២ ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

### ២.៤.២.១ តួនាទី មុខងារ និងអំណាចនៃរដ្ឋបាលឃុំ សង្កាត់

រដ្ឋបាលឃុំ សង្កាត់ ត្រូវដឹកនាំ គ្រប់គ្រងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវមានប្រធានក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់។[១១] តួនាទី មុខងារ និងអំណាចរបស់ឃុំ សង្កាត់ អាចមានសមត្ថកិច្ចតែក្នុងវង្វង់ដែនដីរបស់ខ្លួនតែប៉ុណ្ណោះ។ បន្ទាប់ពីការបោះឆ្នោតនៅឆ្នាំ ២០០២ ក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទីជំរុញ និងគាំពារអភិបាលកិច្ចល្អ ដោយចាត់ចែងប្រើប្រាស់ធនធាននានាដែលប្រកបដោយចិរភាព សំរាប់បំពេញសេចក្តីត្រូវការជាមូលដ្ឋានក្នុងឃុំ សង្កាត់របស់ខ្លួន បម្រើផលប្រយោជន៍រួមរបស់ប្រជាពលរដ្ឋ និងគោរពផលប្រយោជន៍របស់ជាតិស្របតាមនយោបាយទូទៅរបស់រដ្ឋ។

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានរៀបចំ៥អាណត្តិរួចមកហើយ ដែលក្នុងនោះប្រព្រឹត្តិនៅឆ្នាំ២០០២ ឆ្នាំ២០០៧ ឆ្នាំ២០១២ ឆ្នាំ២០១៧ និងបោះចុងក្រោយនៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០២២ដែលទើបកន្លងផុតថ្មីៗនេះ។

រដ្ឋបាលឃុំ សង្កាត់មានតួនាទីពីរប្រភេទ៖

- តួនាទីបំរើកិច្ចការមូលដ្ឋានសំរាប់បម្រើផលប្រយោជន៍ឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួន
- តួនាទីជាភ្នាក់ងារតំណាងរដ្ឋ ក្រោមការចាត់តាំងឬការប្រគល់អំណាចរបស់អាជ្ញាធររដ្ឋ។

ក្នុងនោះដែរ រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចសំខាន់ក្នុងការ៖

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ
- រៀបចំចាត់ចែងសេវាសាធារណៈចាំបាច់ និងមើលការខុសត្រូវឱ្យកិច្ចការទាំងនោះដំណើរការបានល្អ
- លើកទឹកចិត្តឱ្យមានការបង្កើនផាសុកភាព និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ
- ការពារ ថែរក្សាបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ បេតិកភណ្ឌជាតិ
- សំរបសំរួលទស្សនៈរបស់ប្រជាពលរដ្ឋដើម្បីឱ្យមានការយោគយល់អធ្យាស្រ័យទៅវិញទៅមក
- ជម្រុញកិច្ចអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងលើកកំពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- បំពេញកិច្ចការជាទូទៅដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។

រដ្ឋបាលឃុំ សង្កាត់មានភារកិច្ចអនុវត្តទៅតាមច្បាប់ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន

[១១] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា២៥

ពាក់ព័ន្ធ។ ក្នុងករណីនេះ អាជ្ញាធររដ្ឋអាចធ្វើប្រតិភូអំណាចដល់ឃុំ សង្កាត់ ដោយភ្ជាប់ជាមួយនូវការបង្កើន សមត្ថភាព និងផ្តត់ផ្គង់មធ្យោបាយ សម្ភារៈ ថវិកាសម្រាប់អនុវត្ត។ ការធ្វើប្រតិភូកម្មនេះ ត្រូវផ្តល់ចំពោះតែ សមូហភាពរបស់ក្រុមប្រឹក្សាឃុំ សង្កាត់តែប៉ុណ្ណោះ។ រដ្ឋបាលឃុំ សង្កាត់គ្មានអំណាចសម្រេចលើវិស័យ ទាំងឡាយដូចខាងក្រោម៖

- ព្រៃឈើ
- ប្រៃសណីយ៍ និងទូរគមនាគមន៍
- ការពារប្រទេស
- សន្តិសុខជាតិ
- រូបិយវត្ថុ
- នយោបាយក្រៅប្រទេស
- គោលនយោបាយសារពើពន្ធ
- វិស័យផ្សេងទៀតដែលមានចែងក្នុងច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធ។

ឃុំ សង្កាត់មានអំណាចបញ្ញត្តិ និងអំណាចប្រតិបត្តិ៖

**ក. អំណាចបញ្ញត្តិ៖** ធ្វើឡើងតាមរយៈដីកា តាមការសម្រេចរបស់ក្រុមប្រឹក្សាសម្រាប់គ្រប់គ្រងកិច្ចការក្នុង ក្របខណ្ឌ តួនាទី មុខងារ និងអំណាចដែលច្បាប់ប្រគល់ឱ្យ៖

- ដីកាឃុំ សង្កាត់មានប្រសិទ្ធភាពអនុវត្តតែនៅក្នុងរង្វង់ដែនដីរបស់ខ្លួនប៉ុណ្ណោះ
- ដីកាឃុំ សង្កាត់មិនត្រូវផ្ទុយនឹងសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិដែលកម្ពុជាទទួលស្គាល់
- ដីកាដែលផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តិខាងលើនេះ ចាត់ទុកជាមោឃៈដាច់ខាត។

ដីកាឃុំ សង្កាត់ត្រូវធ្វើឡើងតាមការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវចុះហត្ថលេខាដោយ មេឃុំ សង្កាត់។ រដ្ឋបាលឃុំ សង្កាត់ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់ក្នុងឃុំ សង្កាត់របស់ខ្លួននូវ ដីកាដែលបានសម្រេចរួចហើយ។

**ខ. អំណាចប្រតិបត្តិ៖** មានន័យថារដ្ឋបាលឃុំ សង្កាត់៖

- មានសិទ្ធិអនុវត្តសេចក្តីសម្រេចរបស់ខ្លួននៅក្នុងក្របខ័ណ្ឌតួនាទី មុខងារ និងអំណាចរបស់ខ្លួន ដែលច្បាប់បានប្រគល់ឱ្យ
- អំណាចប្រតិបត្តិនេះត្រូវបានធ្វើប្រតិភូកម្មឱ្យទៅមេឃុំ សង្កាត់ជាអ្នកអនុវត្ត។

### ២.៤.២.២ ផែនការអភិវឌ្ឍរដ្ឋបាលឃុំ សង្កាត់

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរៀបចំ អនុម័ត និងអនុវត្តនូវផែនការអភិវឌ្ឍឃុំ សង្កាត់ក្នុងគោលបំណងកំណត់នូវទស្សនវិស័យ កម្មវិធី និងកិច្ចអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន។ ផែនការអភិវឌ្ឍឃុំ សង្កាត់ត្រូវស្របទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ចរបស់ជាតិ និងត្រូវអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងឆ្នាំទី១នៃអាណត្តិរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវពិនិត្យឡើងវិញដើម្បីផ្តល់ទិន្នន័យថ្មីៗជារៀងរាល់ឆ្នាំ ដោយក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន។ ក្នុងការរៀបចំផែនការអភិវឌ្ឍឃុំ សង្កាត់ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់វិធានការដូចតទៅៈ

- វាយតម្លៃអំពីកម្រិតអត្ថិភាពនៃការអភិវឌ្ឍ និងសកម្មភាពអភិវឌ្ឍនៅក្នុងឃុំ សង្កាត់របស់ខ្លួន
- ប្រមូលផ្តុំសេចក្តីត្រូវការក្នុងឃុំ សង្កាត់ និងកំណត់អាទិភាពចំពោះសេចក្តីត្រូវការទាំងនោះដោយផ្អែកទៅលើធនធានទាំងឡាយដែលឃុំ សង្កាត់និងធនធានដែលបានទទួល
- រៀបចំកម្មវិធីដែលអាចឆ្លើយតបនឹងសេចក្តីត្រូវការនានា តាមរយៈការផ្តល់សេវា និងអភិវឌ្ឍ ហើយកម្មវិធីទាំងនេះត្រូវបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់
- ផ្តល់សេវា និងការអភិវឌ្ឍ អនុលោមទៅតាមថវិការបស់ខ្លួន
- ពិនិត្យ តានដាន និងវាយតម្លៃចំពោះលទ្ធផលនៃការអនុវត្តផែនការអភិវឌ្ឍ
- ប្រើប្រាស់លទ្ធផលផ្សេងៗ ដើម្បីវាយតម្លៃអំពីកម្រិតនៃការអភិវឌ្ឍថ្មីៗក្នុងឃុំ សង្កាត់របស់ខ្លួន។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវដឹកនាំការងារឱ្យស្របទៅនឹងផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន និងត្រូវរៀបចំជាលាយលក្ខណ៍អក្សរដោយមានផែនទី ស្ថិតិ និងសំណុំឯកសារពាក់ព័ន្ធផ្សេងៗទៀតភ្ជាប់ជាមួយផង។ ផែនការអភិវឌ្ឍឃុំ សង្កាត់ក៏ត្រូវកំណត់ផងដែរនូវវិធីសាស្ត្រ និងមធ្យោបាយនានាដើម្បីបង្កលទ្ធភាពឱ្យមានការចូលរួមពីប្រជាពលរដ្ឋក្នុងឃុំ សង្កាត់របស់ខ្លួនក្នុងកិច្ចដំណើរការទាំងមូល។

ក្នុងករណីដែលផែនការអភិវឌ្ឍឃុំ សង្កាត់ណាមួយធ្វើឡើងមិនស្របតាមល័ក្ខខ័ណ្ឌដែលបានចែងក្នុងច្បាប់នេះ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវណែនាំឱ្យក្រុមប្រឹក្សាឃុំ សង្កាត់កែតម្រូវផែនការរបស់ខ្លួនឱ្យបានសមស្របក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីថ្ងៃបានទទួលច្បាប់ចម្លងនៃផែនការនោះ។ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការកែសម្រួលផែនការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួនឱ្យបានសមស្របតាមការណែនាំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធ្វើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃរាល់ការអនុវត្តផែនការ កម្មវិធី គម្រោង និងការផ្តល់សេវានានាប្រកបដោយតម្លាភាព និងមានការទទួលខុសត្រូវខ្ពស់។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើសេចក្ដីរាយការណ៍ប្រចាំឆ្នាំអំពី៖

- កិច្ចការជាអាទិភាព គោលដៅសម្រាប់ផ្ដល់សេវា និងគម្រោងផែនការអភិវឌ្ឍរបស់ឃុំ សង្កាត់នាឆ្នាំសារពើពន្ធកន្លងមក
- លទ្ធផលនៃការអនុវត្តចំពោះកិច្ចការជាអាទិភាព គោលដៅសម្រាប់ផ្ដល់សេវា និងគម្រោងផែនការអភិវឌ្ឍទាំងនោះរបស់ឃុំ សង្កាត់
- វិធានការធ្វើឱ្យបានល្អប្រសើរចំពោះវិស័យនានាដែលមានការខ្វះចន្លោះក្នុងការអនុវត្តកន្លងមក
- កិច្ចការជាអទិភាព គោលដៅសម្រាប់ផ្ដល់សេវា និងគម្រោងផែនការអភិវឌ្ឍរបស់ឃុំ សង្កាត់ក្នុងឆ្នាំសារពើពន្ធបច្ចុប្បន្ន។

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវអនុម័តសេចក្ដីរាយការណ៍នេះក្នុងអំឡុងពេលយ៉ាងយូរ ៤៥ថ្ងៃ បន្ទាប់ពីបំណាច់ឆ្នាំសារពើពន្ធនីមួយៗ។ ក្រោយពីបានអនុម័តយល់ព្រមដោយក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ៖

- ចម្លងជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- តម្កល់ទុកជាសាធារណៈ
- ចម្លងចែកជូនអង្គការ សមាគម និងសាធារណៈជនសំខាន់ៗដោយគិតត្រឹមថ្ងៃដើម។

**២.៤.២.៣ ទោសប្បញ្ញត្តិ**

សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលមិនគោរពតាមបទប្បញ្ញត្តិនៃច្បាប់ ត្រូវទទួលវិន័យដោយពុំទាន់គិតដល់ទោសព្រហ្មទ័ណ្ឌផ្សេងទៀត។

វិន័យនោះរួមមាន៖

- ស្ដីបន្ទោសក្នុងអង្គប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានកំណត់ហេតុច្បាស់លាស់
- ករណីនៅតែបន្តប្រព្រឹត្តកំហុស ត្រូវកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ។

វិន័យដែលតម្រូវឱ្យកាត់មួយផ្នែកឬទាំងអស់នូវប្រាក់ឧបត្ថម្ភ លុះត្រាតែមានការយល់ព្រមជាមុនពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ តាមសេចក្ដីស្នើសុំរបស់ក្រុមប្រឹក្សាឃុំ សង្កាត់។ ប្រាក់ឧបត្ថម្ភដែលកាត់នេះត្រូវបានមកជាប្រយោជន៍នៃថវិកាឃុំ សង្កាត់។

ក្នុងករណីបានអនុវត្តរូបភាពវិន័យទាំងពីរខាងលើរួចហើយ តែសាមីខ្លួននៅតែមិនរាងចាល ក្រុមប្រឹក្សាឃុំ សង្កាត់អាចបញ្ចប់ជននោះពីមុខតំណែងជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដោយការបោះឆ្នោតអនុម័តតាមសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ទាំងមូល ហើយត្រូវធ្វើការជ្រើសរើសសមាជិកថ្មីមកជំនួសតាមល័ក្ខខ័ណ្ឌ។

ក្នុងករណីប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ជាមេឃុំ ចៅសង្កាត់ទទួលវិន័យ ត្រូវជ្រើសយកសមាជិកណាម្នាក់ក្រុមប្រឹក្សាឬមន្ត្រីម្នាក់ដែលចាត់តាំងដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឱ្យដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ សង្កាត់ដើម្បីអនុវត្ត។ មន្ត្រីដែលចាត់តាំងដោយមន្ត្រីក្រសួងមហាផ្ទៃឱ្យដឹកនាំកិច្ចប្រជុំខាងលើនេះ ពុំមានសិទ្ធិអនុម័តឡើយ។

មន្ត្រីរាជការដែលប្រព្រឹត្តផ្ទុយពីមាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជាកំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ។ កំហុស និងការឆ្គាំឆ្គងក្នុងវិជ្ជាជីវៈ ត្រូវយកទណ្ឌកម្មខាងវិន័យទៅអនុវត្ត។ ទណ្ឌកម្មខាងវិន័យបែងចែកជា ២ថ្នាក់៖

**ក.ទណ្ឌកម្មថ្នាក់ទី១**

- ស្តីបន្ទោស
- ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិឬថ្នាក់។

**ខ. ទណ្ឌកម្មថ្នាក់ទី២**

- ស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិឬថ្នាក់ ប្រសិនបើមានចុះឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការដំឡើងឋានន្តរស័ក្តិឬថ្នាក់ក្នុងចិរវេលាមួយមានកំណត់ តែមិនត្រូវឱ្យលើសពី០២ឆ្នាំ ក្នុងការដំឡើងឋានន្តរស័ក្តិឬថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាពឡើយ
- ដាក់ឱ្យទំនេរគ្មានបៀវត្សមិនឱ្យលើសពី០១ឆ្នាំ
- បន្ថយឋានន្តរស័ក្តិឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់
- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ឬបញ្ឈប់ពីការងាររាជការដោយបង្ខំ
- បណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ។

នៅពេញដែលមានការចោទប្រកាន់ មន្ត្រីរាជការមានសិទ្ធិប្តឹងតវ៉ាចំពោះការដាក់វិន័យ ដោយអាចទាមទាររកមូលហេតុនៃការដាក់វិន័យដូចខាងក្រោម៖

- សិទ្ធិក្នុងការពិនិត្យសំណុំឯកសាររបស់
- សិទ្ធិសំអាងសាក្សី

- សិទ្ធិក្នុងការជ្រើសរើសអ្នកការពារខ្លួន
- សិទ្ធិក្នុងការពន្យល់ជា លាយលក្ខណ៍អក្សរឬផ្ទាល់មាត់។

**២.៤.៣ គោលការណ៍នៃប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ**

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាពដើម្បីបង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។[១២]

**រដ្ឋបាលឯកភាព** គឺជាការរៀបចំឱ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន ហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យរួមមានសមាសភាពដូចខាងក្រោម៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវភាពរបស់ប្រជាជននៅមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

គោលការណ៍ទាំង៨ខាងលើ គឺជាការកំណត់អំពីមូលដ្ឋានគ្រឹះដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការនៃប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ បែបបទ និតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការរៀបចំច្បាប់ និងលិខិតបទដ្ឋាននានា។ ខ្លឹមសារសំខាន់ៗនៃគោលការណ៍ទាំង៨ មានដូចខាងក្រោម៖

**ទី១៖ ភាពជាតំណាងសាធារណៈ**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការបោះឆ្នោត

[១២] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា២

តាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស គឺជាការផ្តល់ភាពតំណាងសាធារណៈដល់ក្រុមប្រឹក្សាជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើសកម្មភាពនានា ក្នុងនាមផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយមិនមានការរើសអើងខាងនយោបាយ ពណ៌សម្បុរ ជំនឿ សាសនា ជនជាតិ និងទ្រព្យធនឡើយ។

**ទី២៖ ស្វ័យភាពរបស់មូលដ្ឋាន**

ស្វ័យភាពមូលដ្ឋាន មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួនក្នុងដែនសមត្ថកិច្ចដែលច្បាប់បានកំណត់។

**ទី៣៖ ការពិគ្រោះយោបល់ និងការចូលរួម**

ការពិគ្រោះយោបល់ និងការចូលរួម គឺជាកិច្ចដំណើរការដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិស្វែងយល់អំពីបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់សហគមន៍ផ្សេងៗគ្នាក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីរដ្ឋបាលថ្នាក់ក្រោមជាតិដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការដែលមានលក្ខណៈផ្សេងៗគ្នាក្នុងមូលដ្ឋានខ្លួន ( ឧទាហរណ៍ តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ជរា ជនជាតិ ជនក្រីក្រ...ជាដើម ) សំដៅធ្វើសេចក្តីសម្រេចឆ្លើយតបបានកាន់តែប្រសើរទៅនឹងផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៤៖ ការឆ្លើយតប និងគណនេយ្យភាព**

ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរ ចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

**ទី៥៖ ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន**

គឺជាកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើត និងធ្វើឱ្យមាននិរន្តភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តម្រូវការរបស់ប្រជាពលរដ្ឋមានលក្ខណៈផ្សេងៗគ្នាទៅតាមសហគមន៍ និងក្រុមប្រជាពលរដ្ឋដែលមានដូចជាយុវជន ស្ត្រី កុមារ ជនពិការ ចាស់ជរា ជនជាតិដើមភាគតិច និងក្រុមជនក្រីក្រជាដើម ហេតុនេះហើយក្រុមប្រឹក្សាត្រូវតែខិតខំស្វែងយល់ឱ្យបានគ្រប់ជ្រុងជ្រោយ ពីតម្រូវការផ្សេងៗគ្នារបស់អ្នកទាំងនោះ តាមរយៈការលើកកម្ពស់ការពិគ្រោះយោបល់ និងការចូលរួម។ ទន្ទឹមនេះក្រុមប្រឹក្សាត្រូវ

ខិតខំប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួនឱ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

**ទី៦៖ ការលើកស្ទួយសមធម៌**

ជាគោលការណ៍ ទន្ទឹមនឹងការលើកកម្ពស់ការឆ្លើយតប គណនេយ្យភាព និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវលើកស្ទួយសមធម៌សង្គមក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។ ការលើកស្ទួយសមធម៌សង្គម គឺជាកិច្ចដំណើរការដែលតម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រឹងប្រែងធានាឱ្យមានការពិគ្រោះយោបល់ ការចូលរួមកាន់តែស៊ីជម្រៅជាមួយស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ សហគមន៍ក្រីក្រ ជនជាតិភាគតិច។ល។ សំដៅធ្វើការផ្តល់សេវា និងការអភិវឌ្ឍឱ្យបានសមស្របបំផុតចំពោះក្រុមជនទាំងនោះ។ ក្នុងន័យនេះ ការផ្តល់សេវា និងការអភិវឌ្ឍត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ក្រុមជនខាងលើនេះ ដើម្បីឱ្យក្រុមជនទាំងនេះទទួលបាននូវឱកាសកាន់តែច្រើន អត្ថប្រយោជន៍កាន់តែច្រើន ពីការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៧៖ តម្លាភាព និងសុចរិតភាព**

តម្លាភាព និងសុចរិតភាព គឺជាគោលការណ៍ស្នូលនៃអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធានារៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ជាស្ថាប័នប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ជាក្រឹត្យក្រមតម្លាភាព និងសុចរិតភាពមិនអាចកើតឡើងដោយឯកឯងបានឡើយ។ តម្លាភាព និងសុចរិតភាពទាមទារត្រូវរៀបចំឱ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីច្បាស់លាស់សម្រាប់ស្ថាប័ននីមួយៗ ហើយថ្នាក់ដឹកនាំនៃស្ថាប័ននោះត្រូវមានការប្តេជ្ញាចិត្តក្នុងការកសាងស្ថាប័នរបស់ខ្លួនប្រកបដោយតម្លាភាព និងសុចរិកភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សា គណៈអភិបាលត្រូវមានការប្តេជ្ញាចិត្តកសាងរដ្ឋបាលរបស់ខ្លួនឱ្យក្លាយជារដ្ឋបាលដែលមានលក្ខណៈបើកចំហ មានតម្លាភាព ដោយត្រូវធានាឱ្យបានថា សមាជិកក្រុមប្រឹក្សាគ្រប់ៗរូប អភិបាល អភិបាលរង មន្ត្រី បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយតម្លាភាព និងត្រូវប្រកាន់យកគោលការណ៍សុចរិតភាពក្នុងការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចប្រជុំ ជាសាធារណៈរបស់ក្រុមប្រឹក្សា ការប្រជុំគណៈអភិបាល ការកសាងរបៀបធ្វើការជាក្រុមក្នុងក្រុមប្រឹក្សាគណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរបស់ខ្លួន ការរៀបចំ និងដាក់ឱ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យការងារផ្ទៃក្នុង ផ្ទៃក្រៅ និងប្រព័ន្ធនីតិវិធីនានាជាច្រើនដែលបានដាក់ឱ្យប្រើប្រាស់កន្លងមកនេះ គឺមានគោលបំណងគាំទ្រដល់ការលើកកម្ពស់តម្លាភាព និងសុចរិតភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**ទី៨៖ វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច**

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច គឺជាកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈគ្រប់

ថ្នាក់ ផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ៗរូប សំដៅកសាងសង្គមមួយប្រកបដោយភាពស្អាតស្អំ និង យុត្តិធម៌ដើម្បីធានាឱ្យមានការអភិវឌ្ឍសង្គមប្រកបដោយចីរភាព និងសមធម៌។

### ២.៤.៣.១ ការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ

#### ក. ឋានៈផ្លូវច្បាប់

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺជានីតិបុគ្គលនៃនីតិសាធារណៈ។[១៣] នីតិបុគ្គល នីមួយៗ រួមមានដែនដី និងប្រជាពលរដ្ឋនៅក្នុងដែនដីនោះ និងមានក្រុមប្រឹក្សាមួយជាតំណាងដែលកើតឡើងពី ការបោះឆ្នោតជ្រើសរើស ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុម ប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ការផ្តល់ភាពជានីតិបុគ្គល ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺក្នុងគោល បំណងផ្តល់សិទ្ធិអំណាច មុខងារ ធនធាន និងទ្រព្យសម្បត្តិឱ្យដល់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាអាចគ្រប់គ្រង ចាត់ចែងកិច្ចការនានានៅមូលដ្ឋាន សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និង អភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព ប្រសិទ្ធភាព សមធម៌ និងបរិយាប័ន្ន។

#### ខ. ក្រុមប្រឹក្សា

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិរួមមាន ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសឡើងតាមរយៈការ បោះឆ្នោតជាសកល និងក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះ ឆ្នោតជាអសកល។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានអាណត្តិ៥ឆ្នាំ និងផុតកំណត់នៅពេលក្រុមប្រឹក្សា ថ្មីចូលកាន់តំណែង។

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ក្រុម ប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការចេញដីកា និងសិទ្ធិអំណាចខាងប្រតិបត្តិតាមរយៈការធ្វើ សេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។

#### គ. បុគ្គលិក

ក្រុមប្រឹក្សានីមួយៗមានបុគ្គលិករបស់ខ្លួន ដែលរួមមានបីប្រភេទដូចខាងក្រោម៖

- បុគ្គលិកដែលបានតែងតាំងដោយក្រុមប្រឹក្សា
- បុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា

[១៣] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ មាត្រា៩

- បុគ្គលិកដែលបានរៀបចំឡើងវិញឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា។

ក្រុមប្រឹក្សាត្រូវសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត សម្រាប់មុខតំណែងបុគ្គលិករបស់ខ្លួន ស្របតាម ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

បុគ្គលិករបស់ក្រុមប្រឹក្សាត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយផ្ទាល់របស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

**២.៤.៣.២ ការបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា**

ក្រុមប្រឹក្សាខេត្ត មានកាតព្វកិច្ចបង្កើតគណៈកម្មាធិការពិគ្រោះយោបល់ចំនួនបី ដែលរួមមាន៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

ក្រៅពីគណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើនេះ ក្រុមប្រឹក្សាខេត្តអាចបង្កើតគណៈកម្មាធិការបន្ថែមផ្សេងទៀតតាមការចាំបាច់។ គណៈកម្មាធិការដែលបង្កើតបន្ថែមមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយនឹងតួនាទី និងភារកិច្ចរបស់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើឡើយ។[១៤] ជាមួយនេះដែរ ក្រុមប្រឹក្សាខេត្តអាចបង្កើតអនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងៗទៀត តាមការស្នើសុំរបស់គណៈកម្មាធិការនានា ឬគណៈអភិបាលខេត្ត។ អនុគណៈកម្មាធិការ ឬក្រុមការងារខាងលើនេះត្រូវមានគណនេយ្យភាពជាបឋមជាមួយគណៈកម្មាធិការ ឬគណៈអភិបាលខេត្ត។

ក្នុងការរៀបចំបង្កើតគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាខេត្តត្រូវពិនិត្យពិចារណាលើចំណុចមួយចំនួនដូចខាងក្រោម៖

- ក្រុមប្រឹក្សាខេត្តអាចតែងតាំងសមាជិកក្រុមប្រឹក្សាខេត្ត អភិបាលខេត្ត អភិបាលរងខេត្ត បុគ្គលិករបស់ក្រុមប្រឹក្សាខេត្ត តំណាងក្រុមប្រឹក្សាប្រភេទផ្សេងទៀតក្នុងដែនសមត្ថកិច្ចរបស់ខេត្ត តំណាងសហគមន៍ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាតាមការចាំបាច់ ជាសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើង។
- ក្រុមប្រឹក្សាខេត្ត ត្រូវសម្រេចពីចំនួនសមាជិកគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ការតែងតាំងប្រធាន អនុប្រធាន និងកំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការ ឬ

[១៤] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១១៥ វាក្យខណ្ឌ

អនុគណៈកម្មាធិការ ឬក្រុមការងារនានាដែលខ្លួនបានបង្កើតឡើង។

- គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនីមួយៗ ត្រូវមានតំណាងស្ត្រីសមស្រប រួមទាំងតំណែងប្រធាន ឬអនុប្រធានគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារផង។
- ក្រុមប្រឹក្សាខេត្តអាចរំសាយគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារ និងអាចបញ្ឈប់សមាជិកណាម្នាក់ពីគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលខ្លួនបានបង្កើតឡើងតាមការចាំបាច់ ឬតាមសំណើរបស់គណៈកម្មាធិការ ឬគណៈអភិបាលខេត្ត។
- គណៈអភិបាលខេត្តអាចស្នើសុំក្រុមប្រឹក្សាខេត្ត ដើម្បីឱ្យគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារណាមួយ ដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង រួមទាំងគណៈកម្មាធិការជាកាតព្វកិច្ចទាំងបី ជួយសិក្សាផ្តល់យោបល់លើបញ្ហាណាមួយ ឬមួយចំនួនដែលស្ថិតក្នុងសមត្ថកិច្ចរបស់គណៈអភិបាលខេត្ត។
- ក្រុមប្រឹក្សាខេត្តត្រូវទទួលខុសត្រូវរាល់ការសម្រេច និងសកម្មភាពរបស់គណៈកម្មាធិការនានា និងទទួលខុសត្រូវចំពោះផលវិបាកនានា ដែលកើតចេញពីសកម្មភាពរបស់គណៈកម្មាធិការទាំងនោះ។
- ក្រុមប្រឹក្សាខេត្ត ត្រូវណែនាំឱ្យគណៈអភិបាលខេត្តឱ្យផ្តល់ការគាំទ្រកិច្ចការផ្នែកលេខាធិការដ្ឋាន ការគាំទ្រផ្នែកច្បាប់ និងបច្ចេកទេស ព្រមទាំងការគាំទ្រដទៃទៀតដល់គណៈកម្មាធិការជាកាតព្វកិច្ចទាំងបី ឬដល់គណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារដែលក្រុមប្រឹក្សាខេត្តបានបង្កើតឡើង។
- គណៈកម្មាធិការដែលបានបង្កើតឡើង ត្រូវមានសេចក្តីរាយការណ៍ប្រចាំត្រីមាស ឆមាស ឆ្នាំ និងតាមតម្រូវការចាំបាច់នានា។ សេចក្តីរាយការណ៍ទាំងនេះ ត្រូវចម្លងជូនគណៈអភិបាលខេត្ត ដើម្បីធ្វើការបូកសរុប និងរាយការណ៍ជូនក្រុមប្រឹក្សាខេត្ត។
- ក្រុមប្រឹក្សាខេត្ត អាចតម្រូវឱ្យគណៈកម្មាធិការណាមួយធ្វើសេចក្តី រាយការណ៍ដោយផ្ទាល់អំពីកិច្ចការពិសេស និងបន្ទាន់ណាមួយក្នុងកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

# ជំពូកទី៣

# លទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយ
# នៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

# ជំពូកទី៣
# លទ្ធផល បញ្ហាប្រឈម និងដំណោះស្រាយនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

## ៣.១ លទ្ធផលដែលទទួលបានក្នុងការអនុវត្តកន្លងមក

កំណែទម្រង់បានប្រព្រឹត្តទៅជា ៣ដំណាក់កាលៈ

១. ការពង្រឹងគ្រឹះនៃការគ្រប់គ្រងមុខងារសាធារណៈ។

២. ការរៀបចំសម្រួលរចនាសម្ព័ន្ធ និងការពង្រាយមន្ត្រីរាជការ។

៣. ការធ្វើសនិទានកម្មមុខងារសាធារណៈ និងអភិវឌ្ឍធនធានមនុស្ស។

ដំណាក់កាលនីមួយៗត្រូវបានអនុវត្តដោយផ្អែកលើអ័ក្ស៤គឺៈ

១. ពង្រឹងស្ថាប័នរដ្ឋដោយពង្រឹងនីតិរដ្ឋក្នុងរដ្ឋបាល។

២. កែលម្អប្រព័ន្ធរដ្ឋបាល និងអន្តរសកម្មរវាស្ថាប័នតាមរយៈការពង្រឹងការងារអភិបាលកិច្ចល្អ។

៣. អភិវឌ្ឍធនធានមនុស្ស ដើម្បីពង្រឹងប្រសិទ្ធភាពរដ្ឋបាលសាធារណៈ។

៤. គ្រប់គ្រងការផ្លាស់ប្តូរ។

សមិទ្ធផលដែលសម្រេចបានក្នុងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរួមមានៈ

- បានធ្វើជំរឿនមន្ត្រីរាជការស៊ីវិលទូទាំងប្រទេស ដោយបានរកឃើញ និងលុបចេញពីក្របខណ្ឌនូវមន្ត្រីដែលមានឈ្មោះក្នុងបញ្ជី (មន្ត្រីខ្មោច) និងមន្ត្រីមិនប្រក្រតីផ្សេងៗទៀតចំនួនជាង ១ម៉ឺននាក់
- បានកសាងមូលដ្ឋានទិន្នន័យសម្រាប់គ្រប់គ្រងមន្ត្រីរាជការស៊ីវិល
- ការផ្តល់សេវាជូនប្រជាពលរដ្ឋប្រកបដោយប្រសិទ្ធភាព តម្លាភាព និងភាពស្វាហាប់ក្នុងការបំពេញការងារ
- មន្ត្រីរាជការកាន់តែមានសមត្ថភាព
- បង្កើតលក្ខន្តិកៈដោយឡែកតាមប្រភេទក្របខ័ណ្ឌរបស់មន្ត្រីរាជការស៊ីវិលចំនួន២១ប្រភេទក្របខណ្ឌ
- បង្កើត និងដាក់ឱ្យអនុវត្តប្រព័ន្ធលាភការថ្មី
- ធ្វើសមាហរណកម្មមន្ត្រីរាជការស៊ីវិលតាមប្រព័ន្ធលាភការថ្មី
- បង្កើត និងដាក់ឱ្យដំណើរការតារាងទូទាត់បៀវត្សតាមប្រព័ន្ធព័ត៌មានវិទ្យា

- រៀបចំឱ្យមានប្រាក់បំណាច់មុខងារតាមវិស័យជូនមន្ត្រីស៊ីវិល
- ដំឡើងប្រាក់បៀវត្សជូនមន្ត្រីរាជការស៊ីវិលជាបន្តបន្ទាប់
- កសាងគោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ
- ចងក្រងកម្រងព័ត៌មានសេវាសាធារណៈ
- កំណត់ក្របខណ្ឌមន្ត្រីរាជការស៊ីវិលតាមលក្ខន្តិកៈដោយឡែកនៃប្រភេទក្របខណ្ឌនីមួយ
- កែសម្រួលគោលនយោបាយធានារ៉ាប់រងសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល
- ចូលរួមបង្កើតឱ្យមានបេឡាជាតិសន្តិសុខសង្គមសម្រាប់រាជការស៊ីវិល
- ពង្រឹងការគ្រប់គ្រង និងត្រួតពិនិត្យក្របខណ្ឌមន្ត្រីរាជការ
- ចងក្រង បោះពុម្ព និងផ្សព្វផ្សាយកម្រងព័ត៌មានសេវាសាធារណៈ
- រៀបចំអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈកម្មាធិការជាតិវាយតម្លៃសេវាសាធារណៈ
- បង្កើតគោលនយោបាយធនធានមនុស្សក្នុងរដ្ឋបាលសាធារណៈ
- បង្កើតឯកសារណែនាំស្តីពីស្តង់ដាសេវាសាធារណៈ
- លើកកម្ពស់សមត្ថភាពមន្ត្រីរាជការតាមរយៈការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស
- ដាក់ឱ្យអនុវត្តកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមរយៈទូរស័ព្ទស្មាតហ្វូន
- ច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាធារណៈ
- ដាក់ឱ្យអនុវត្តការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាសាធារណៈគំរូក្នុងវិស័យអប់រំ និងសុខាភិបាល ។

ទន្ទឹមនេះ រាជរដ្ឋាភិបាល បានកែសម្រួលគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ និងពន្លឿននីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឱ្យចូលនិវត្តន៍ បានដាក់ឱ្យអនុវត្តលក្ខន្តិៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទដ្ឋានគតិយុត្តិនានា និងឯកសារណែនាំមួយចំនួនទៀតដើម្បីពង្រឹងការគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិល មន្ត្រីកិច្ចសន្យា ការគ្រប់គ្រងរចនាសម្ព័ន្ធ និងចំនួនមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ព្រមជាមួយនឹងការធ្វើប្រតិភូកម្មអំណាចក្នុងការតែងតាំងផ្លាស់ប្តូរ និងបញ្ជាប់ភារកិច្ចទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បានដាក់ចេញនូវការណែនាំ និងគំរូនៃការរៀបចំការពិពណ៌នាមុខតំណែងសម្រាប់មុខតំណែងគ្រប់គ្រងដល់គ្រប់ក្រសួង ស្ថាប័ន។ រាជរដ្ឋាភិបាលបានរៀបចំវគ្គបណ្តុះបណ្តាលជាប្រព័ន្ធ និងជាកាតព្វកិច្ចដល់មន្ត្រីរាជការ តាមរយៈសាលាភូមិន្ទរដ្ឋបាលដោយផ្តោតទៅលើការបណ្តុះ

បណ្តាលសម្រាប់កម្រិតថ្នាក់ដឹកនាំ កម្រិតគ្រប់គ្រង និងមន្ត្រីក្របខណ្ឌថ្មីព្រមទាំងកម្រិតថ្នាក់ដឹកនាំជាស្ត្រី។

ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាល រៀបចំប្រព័ន្ធបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធឱ្យមានសង្គតិភាព ក្នុងនោះបានដំឡើងប្រាក់បៀវត្ស ប្រាប់ឧបត្ថមផ្សេងៗជូនដល់មន្ត្រីរាជាការកម្រិតអប្បបរ-មាទទួលបានច្រើនជាងមួយលានរៀល និងបើកផ្តល់បានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ តាមប្រព័ន្ធធនាគារ និងបានដាក់ឱ្យអនុវត្តការកាត់ពន្ធបៀវត្សប្រចាំខែរបស់មន្ត្រីរាជាការស៊ីវាលដោយស្វ័យប្រវត្តិ ព្រមទាំងបានដាក់ឱ្យអនុវត្តការផ្តល់ប្រាក់វិភាជន៍គ្រួសារសម្រាប់កូនមន្ត្រីរាជការរហូតដល់អាយុ២១ឆ្នាំដោយស្វ័យប្រវត្តិ។ ទន្ទឹមនេះ រាជរដ្ឋាភិបាលបានដំឡើងប្រាក់សោធននិវត្តន៍ប្រចាំខែជូននិវត្តន៍ជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈដែលជាអតីតមន្ត្រីរាជការស៊ីវិល ព្រមទាំងបានដំឡើងប្របាក់ឧបត្ថម្ភ មាតុភាពជូនមន្ត្រីរាជាការ មន្ត្រីកម្មសិក្សា និងមន្ត្រីជាប់កិច្ចសន្យាជាស្ត្រីដែលសម្រាលកូន និងប្រាក់ឧបត្ថម្ភបុណ្យសព ។

ក្រៅពីនេះ រាជរដ្ឋាភិបាល បានដំឡើងប្រាក់បំណាច់មុខងារ ប្រាក់កម្រៃ ប្រាក់ឧបត្ថម្ភ ប្រាប់បំណាច់ និងបច្ច័យនិច្ចជូនដល់ មន្ត្រីរាជការ មន្ត្រីកិច្ចសន្យា កងកម្លាំងប្រដាប់អាវុធ សមាជិករាជរដ្ឋាភិបាល ទីប្រឹក្សាជំនួយការ លេខាធិការនិងមន្ត្រីដែលមានឋានៈស្មើ មន្ត្រីខុទ្ទការល័យ គ្រពុទ្ធិកសិក្សា ចៅក្រមនិងព្រះរាជអាជ្ញា សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ និងមន្ត្រីភូមិព្រមទាំងផ្តល់ជូននូវប្រាក់ឧបត្ថមសម្រាប់សហព័ទ្ធ និងកូនរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជាករនិងបុគ្គលិកបំពេញភារកិច្ចតាមស្ថានតំណាងកម្ពុជានៅបរទេស និងប្រាក់តំបន់សម្រាប់វិស័យអប់រំនិងវិស័យសុខាភិបាល។

### ៣.២ បញ្ហាប្រឈមក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ការគ្រប់គ្រងរដ្ឋទាមទារអោយមានការរៀបចំរដ្ឋបាលមួយច្បាស់លាស់ទៅតាមរបបនៃរដ្ឋ។ រដ្ឋបាលកណ្តាលឬរដ្ឋបាលថ្នាក់ជាតិ គឺជាបណ្តុំនៃអាជ្ញាធរជាច្រើនរួមគ្នាដែលបង្កើតបានជាអំណាចមួយដែលមានឈ្មោះថា នីតិប្រតិបត្តិ។ រដ្ឋបាលកណ្តាលនេះមានតួនាទីបំពេញមុខងាររដ្ឋបាលនៅថ្នាក់ខ្ពស់បំផុត និងស្ថិតក្រោមក្របខណ្ឌជាតិទាំងស្រុងហើយអំណាចកណ្តាលគឺជាអ្នកមានសមត្ថកិច្ចដឹកនាំជាតិទាំងមូលដោយផ្ទាល់ឬក៏តាមរយៈតំណាងនានារបស់រដ្ឋភិបាលនៅថ្នាក់ក្រោមជាតិ។

ដូច្នេះហើយទើបមានបញ្ហាប្រឈមមួយចំនួនដូចជាៈ

- នីតិវិធីមួយចំនួនក្នុងការផ្តលសេវាសាធារណៈនៅមានភាពស្មុគស្មាញ ប្រមូលផ្តុំ ការិយាធិបតេយ្យ។ ទន្ទឹមនឹងនេះ ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាមួយចំនួននៅក្នុងរដ្ឋបាលសាធារណៈនៅមានកម្រិត ហើយការរៀបចំ និងការយកចិត្តទុកដាក់ឱ្យអនុវត្តមួយចំនួនមានលក្ខណៈដាច់ដោយដុំ និងមានលក្ខណៈជាប្រព័ន្ធ។
- លំហូរការងារ និងទំនាក់ទំនងផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន និងរវាងក្រសួង ស្ថាប័ន និងក្រសួង ស្ថា-

ប័ន នៅមិនទាន់ដំណើរការជាបណ្តាញតភ្ជាប់ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងមានភាពរលូននៅឡើយ។

- យន្តការ និងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពនៃសេវាសាធារណៈមិនទាន់បានដាក់ឱ្យដំណើការប្រកបដោយប្រសិទ្ធភាព
- ការងារគ្រប់គ្រង និងការអភិវឌ្ឍអាជីពរបស់មន្ត្រីរាជការ មិនទាន់បានរៀបចំជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងមិនទាន់មានការៀបចំការពិពណ៌នាអំពីមុខតំណែងឱ្យបានច្បាស់លាស់នៅឡើយ។
- សមត្ថភាពធនធានមនុស្ស និងស្ថាប័ននៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ពលរដ្ឋ ពិសេសនៅថ្នាក់ក្រោមជាតិ។
- ប្រព័ន្ធបៀវត្សមិនទាន់ឆ្លើយតបទៅនឹងគោលការសមធម៌ ប្រសិទ្ធភាព សង្គតិសាស្ត្រ ក្នុងនោះគម្លាតបៀវត្សមន្ត្រីរាជការនៅមានកម្រិតខ្ពស់ប្រព័ន្ធបៀវត្តរបស់កងកម្លាំងប្រដាប់អាវុធ និងមន្ត្រីរាជការ និងមន្ត្រីរាជការស៊ីវិមិនទាន់មានសង្គតិនឹងគ្នា។

**សង្គតិសាស្ត្រ**

សង្គតិៈ ការរាប់រកគ្នា ការរាប់អានគ្នា សេចក្តីស្មោះស្មើទៅវិញទៅមករកគ្នា ការរួបរួមគ្នា ការប្រជុំ ការជួបជុំគ្នា សមាគមជាដើម។

សាស្ត្រៈ គម្ពីរ ច្បាប់ ក្បួន តម្រា ពាក្យណែនាំ ពាក្យពន្យល់ និងពាក្យបង្គាប់ជាដើម។

**សង្គតិសាស្ត្រៈ** គឺជាសេចក្តីស្មោះស្មាក់ ការរួបរួមគ្នាក្នុងការអនុវត្តទៅតាមច្បាប់។[១៥]

រាជរដ្ឋាភិបាលចាត់ទុកកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ គឺជាមធ្យោបាយដ៏មានប្រសិទ្ធិភាពក្នុងការបង្វិតសេវាសាធារណៈឱ្យកាន់តែទៅជិតប្រជាពលរដ្ឋ ហើយរំពឹងថានឹងទទួលបាននូវផលប្រយោជន៍ធំៗចំនួន៣ដូចខាងក្រោម ៖

- ប្រជាពលរដ្ឋអាចមានលទ្ធភាពចូលរួមយ៉ាងសកម្មនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តនៅមូលដ្ឋាន ដែលនេះ គឺជាការពង្រឹង និងពង្រីកនូវការចូលរួមជាសាធារណៈ នៅក្នុងការអភិវឌ្ឍប្រទេសជាតិ ។ ផ្អែកលើលទ្ធផលនៃការចូលរួមនេះ តម្រូវការ និងអាទិភាពនានារបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ត្រូវបានគិតគូរយកចិត្តទុកដាក់ និងឆ្លើយតបកាន់តែប្រសើរឡើង។ ដូច្នេះ តាមរយៈការអនុវត្តកំណែទម្រង់នេះ នឹងនាំឱ្យមានការធ្វើសេចក្តីសម្រេចចិត្តកាន់តែប្រសើរ និងការប្រើប្រាស់ធនធានកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិថែមទៀត។
- ការផ្តល់សេវាសាធារណៈរបស់ក្រសួង ស្ថាប័ននៅថ្នាក់ជាតិកាន់តែរហ័ស និងមានប្រសិទ្ធភាព ព្រោះ

[១៥] កម្មវិធីទូរស័ព្ទដៃ វចនានុក្រមព្រះសង្ឃ រាជជួនណាត

អ្នកទទួលខុសត្រូវក្នុងការផ្តល់សេវាទាំងនោះត្រូវបានផ្ទេរឬបង្វិលឱ្យទៅជិតប្រជាពលរដ្ឋ ។

- ការបង្កើតនូវលទ្ធភាពនៃការកៀរគរប្រភពធនធាននៅមូលដ្ឋានសម្រាប់ផ្តល់សេវា និងការអភិវឌ្ឍបន្ថែមទៀត ដោយផ្អែកលើឆន្ទៈនៃការចូលរួមរបស់ប្រជាពលរដ្ឋ សង្គមស៊ីវិល ក៏ដូចជាការកៀរគរធនធានរបស់វិស័យឯកជននានាឱ្យចូលរួមជាមួយធនធានរបស់អាជ្ញាធរមូលដ្ឋានក្នុងការវិនិយោគលើការអភិវឌ្ឍមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ ។

## ៣.៣ ដំណោះស្រាយក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យត្រូវ៖

- ចាត់វិធានទៅតាមតំបន់អោយផ្សព្វផ្សាយនូវនិតិវិធី និងសិទ្ធរបស់ប្រជាពលរដ្ឋក្នុងការបញ្ចេញមតិ និងធ្វើការរាយការណ៍ពីគុណវិបត្តិរបស់មន្ត្រីរាជការដែលអនុវត្តច្បាប់។
- មុខងារសាធារណៈទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិត្រូវបានរៀបចំជាអង្គវិជ្ជាជីវៈ និងមានការកំណត់មុខតំណែង និងការពិពណ៌នាមុខតំណែងច្បាស់លាស់។
- ការកសាងសមត្ថភាពមន្ត្រីរាជការមានប្រសិទ្ធភាព និងមានប្រព័ន្ធវាយតម្លៃច្បាស់លាស់។
- ប្រព័ន្ធបៀវត្សមន្ត្រីរាជការមានសង្គតិភាព សមធម៌ និងគាំទ្រផលិតភាព។
- ការវិភាគមុខងារ និងការត្រួតពិនិត្យប្រតិបត្តិការឡើងវិញរបស់ក្រសួង ស្ថាប័ន ត្រូវបានអនុវត្ត និងធ្វើការវិចារណកម្ម។
- ប្រព័ន្ធគ្រប់គ្រងគុណផលការងារ និងប្រព័ន្ធលើកទឹកចិត្ត ត្រូវបានដាក់ឱ្យដំណើរការ។
- ប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ ត្រូវបានដាក់ឱ្យអនុវត្ត។
- ជួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នីមួយៗឱ្យបង្កើត ជំរុញ និងធ្វើឱ្យមានចរិភាព សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។
- រួមជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណៈជន នៅក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់។
- ស្វែងយល់ និងឆ្លើយតប ចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងសំណើររបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់។
- បន្តធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលរវាងកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ជាមួយនឹងកម្មវិធីជាតិសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីប្រែក្លាយរដ្ឋបាលថ្នាក់ក្រោមជាតិទៅជាអ្នកផ្តល់សេវា។

- សាធារណៈប្រកបដោយប្រសិទ្ធភាព។
- កំណត់ និងបញ្ជាក់ឱ្យកាន់តែច្បាស់នូវទស្សនាទានសំខាន់ៗ ដូចជាទស្សនាទានស្តីពី រដ្ឋបាលឯកភាព និងភាពខុសគ្នារវាង មុខងារជាកាតព្វកិច្ច និង មុខងារជាជម្រើស។
- បន្តធ្វើវិមជ្ឈការថវិកាបន្ថែម ជូនទៅថ្នាក់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីគាំទ្រដល់ការកែលម្អការផ្តល់សេវាសាធារណៈ។ ទោះការផ្តល់សេវាសង្គមសំខាន់ៗ ដូចជាវិស័យអប់រំ និងសុខាភិបាល បានអនុវត្តវិមជ្ឈការបានច្រើនហើយក៏ដោយ សេវាសំខាន់ៗផ្សេងទៀតជាពិសេសនៅក្នុងវិស័យសង្គមកិច្ច នៅមានការគ្រប់គ្រងបែបមជ្ឈការច្រើននៅឡើយ។
- បង្កើនចំណែកនៃចំណាយសាធារណៈរបស់ថ្នាក់ក្រោមជាតិ។ ការបែងចែកថវិកាសម្រាប់ ថ្នាក់ក្រោមជាតិ មានការកើនឡើងចាប់តាំងពីឆ្នាំ២០១៧មក ប៉ុន្តែថវិកានោះមានប្រហែលត្រឹម ១០ ភាគរយ ប៉ុណ្ណោះនៃថវិកាជាតិសរុប។ សម្រាប់រដ្ឋបាលថ្នាក់ស្រុក ក្រុង ខណ្ឌ ទោះត្រូវមានមុខងារសំខាន់ក្នុងការផ្តល់សេវាសាធារណៈក៏ដោយ តែរដ្ឋបាលកម្រិតនេះនៅទទួលបានថវិកាក្នុងកម្រិតតិចតួច។
- បន្តកែសម្រួលយន្តការផ្ទេរថវិកាសម្រាប់ថ្នាក់ក្រោមជាតិ ដើម្បីឆ្លុះបញ្ចាំងនូវការផ្ទេរមុខងារ និងដើម្បីជំរុញការផ្តល់ថវិកាឱ្យបានកាន់តែច្រើនជាងមុនទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- ការពង្រឹងប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅថ្នាក់ក្រោមជាតិបន្ថែមទៀត ។

ក្នុងករណីដែលក្រុមប្រឹក្សាស្រុកបានប្រឹងប្រែងសម្របសម្រួលបង្កើនសមត្ថភាពផ្នែករដ្ឋបាលឬធនធានផ្នែករដ្ឋបាលដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់រួចហើយ ប៉ុន្តែក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នោះនៅតែមិនអាចបំពេញភារកិច្ចជាមូលដ្ឋាន និងចាំបាច់របស់ខ្លួនបានឬមិនអាចជំរុញការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យបានគ្រប់គ្រាន់ ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ ដើម្បីរាយការណ៍ជាលាយលក្ខណ៍អក្សរជាបន្ទាន់ទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[១៦]

នៅពេលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឯកភាពតាមរបាយការណ៍របស់ក្រុមប្រឹក្សាស្រុក រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវធ្វើការពិគ្រោះពិភាក្សាជាមួយក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធ ដើម្បីរៀបចំផ្តល់ការគាំទ្រដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ឱ្យមានសមត្ថភាពក្នុងការជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យឱ្យមានប្រសិទ្ធភាព។[១៧]

១៦ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១០៣ វាក្យខណ្ឌ១

១៧ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មាត្រា១០៤

# សេចក្តីសន្និដ្ឋាន

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាកំណែទម្រង់ផ្នែកអភិបាលកិច្ចដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិបាល ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០១មក និងបានបង្កើតនូវសមិទ្ធផលជាច្រើនពាក់ព័ន្ធទៅនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ តាមរយៈការអនុវត្តកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានបំពេញតួនាទី និងការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ការទទួលមតិយោបល់ និងការផ្តល់សេវាសាធារណៈនានាឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងដោះស្រាយបញ្ហាប្រឈមជាអាទិភាពនានានៅតាមមូលដ្ឋាន ដែលជួយលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ពិតណាស់ថា ក្នុងរយៈពេលជាច្រើនឆ្នាំមកនេះ រាជរដ្ឋាភិបាលកម្ពុជា បានធ្វើការជាច្រើន ដូចជាលិខិតបទដ្ឋានគតិយុត្ត ដើម្បីដាក់ឱ្យអនុវត្ត ក្នុងការផ្តល់សិទ្ធិអំណាចជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអភិវឌ្ឍនៅថ្នាក់មូលដ្ឋាន។ ប៉ុន្តែការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅមានបញ្ហាប្រឈមជាច្រើនដូចជា ការមិនច្បាស់លាស់នៅភារកិច្ចរបស់ខ្លួន លំហូរការងារមិនមានភាពរលូន សមត្ថភាពធនធានមនុស្ស និងស្ថាប័នមិនឆ្លើយតបជាមួយប្រជាជន អាទិភាពនៃការកំណត់ និងអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល លើការកែទម្រង់វិមជ្ឈការ អំពីអ្វីដែលត្រូវធ្វើមុន។ បច្ចុប្បន្ននេះ កំណែទម្រង់នេះបានឈានចូលដល់ដំណាក់កាលកាន់តែស៊ីជម្រៅ ដោយតម្រូវអោយមានការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈនានា ដែលកំពុងមានការកើនឡើងយ៉ាងគំហុក ស្របពេលដែលស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ជាតិកំពុងមានការរីកចម្រើនកាន់តែខ្ពស់ខ្លាំង។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានរៀបចំ អនុវត្ត និងដោះស្រាយបញ្ហាប្រឈមនានាផ្អែកតាមស្ថានភាពជាក់ស្តែងរបស់កម្ពុជា និងផ្អែកតាមគោលនយោបាយ ច្បាប់ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្នុងគោលបំណងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់ខឿនសេដ្ឋកិច្ចនៅមូលដ្ឋាន ផ្តល់សិទ្ធិសម្រាប់ប្រជាពលរដ្ឋ កាត់បន្ថយភាពក្រីក្រ និងព្រមទាំងលើកកម្ពស់សេវាសាធារណៈ។ ដូច្នេះការគ្រប់គ្រងតាមបែបវិមជ្ឈការ និងវិសហមជ្ឈការធ្វើអោយការអនុវត្តមុខងារកាន់តែមានតម្លាភាព ប្រសិទ្ធភាព និងគណនេយ្យភាពស្របតាមគោលនយោបាយ លិខិតបទដ្ឋាន និងស្តង់ដាដែលបានកំណត់ជាធរមាន។

# អនុសាសន៍

បន្ទាប់ពីបានសិក្សាស្រាវជ្រាវរួចមក គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការជាចំណែកមួយយ៉ាងធំក្នុងការអភិវឌ្ឍប្រទេសជាតិ។ កំណែទម្រង់ប្រព័ន្ធវិមជ្ឈការ និងវិសហមជ្ឈការនេះបានផ្តល់នូវការចូលរួមរបស់ប្រជាពលរដ្ឋ ដៃគូអភិវឌ្ឍន៍ដែលជាធាតុចូលរួមយ៉ាងសំខាន់មិនអាចខ្វះបាន ព្រោះកំណែទម្រង់នេះត្រូវការធាតុចូលដ៏ចាំបាច់ពីពលរដ្ឋដើម្បីបំផុសនូវគំនិតផ្តួចផ្តើម ស្វែងរកតម្រូវការចាំបាច់ឈានទៅអភិវឌ្ឍឱ្យចំគោលដៅរបស់ពលរដ្ឋចង់បាន។ យ៉ាងណាមិញ បើទោះបីជាគោលនបាយនេះអនុវត្តជាយូរមកហើយក៏ដោយ ប៉ុន្តែនៅមានកង្វះខាតនៅឡើយ។ ដូច្នេះកត្តាដែលអាចជួយអោយកំណែទម្រង់វិម-ជ្ឈការ និងវិសហមជ្ឈការដំណើរការឱ្យកាន់តែមានប្រសិទ្ធិភាពរួមមានៈ

១. អាជ្ញាធរថ្នាក់លើ

- បង្កើតក្រុមសើបអង្កេតក្នុងគោលបំណងតាមដានសកម្មភាពរបស់រដ្ឋបាលតំបន់ និងរដ្ឋបាលថ្នាក់មូលដ្ឋាន ព្រមទាំងដកអាជ្ញា។
- ចុះត្រួតពិនិត្យ និងប្រមូលទិន្នន័យពីប្រជាពលរដ្ឋជាប្រចាំពីប្រជាពលរដ្ឋ។ឧទាហរណ៍៖ ពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើខុសច្បាប់ ដូចជាការទទួលសំណូក និងការប្រើប្រាស់ពាក្យសំដីទៅកាន់ប្រជាពលរដ្ឋជាដើម។
- បែងចែកមុខងារអោយបានត្រឹមត្រូវ ជៀសវាងការក្តាប់កិច្ចការមិនជុំ និងធ្វើអោយស្ទះការងារនៅថ្នាក់កណ្តាល។
- ចុះណែនាំអំពីមុខងារ និងវិន័យរបស់សមត្ថកិច្ចនៅក្នុងមូលដ្ឋាននីមួយៗ។

២. ប្រជាពលរដ្ឋក្នុងមូលដ្ឋាន

- ចូលរួមផ្តល់មតិយោបល់ និងបង្ហាញពីគុណវិបត្តិរបស់មន្ត្រីរាជក្នុងការអភិវឌ្ឍតំបន់របស់ខ្លួន។
- ចូលរួមប្រជុំជាមួយអាជ្ញាធរមូលដ្ឋានដើម្បីយល់ដឹងអោយកាន់តែច្បាស់ពីប្រព័ន្ធរដ្ឋបាល និងជាពិសេសនោះស្វែងយល់ពីសិទ្ធ និងកាតព្វកិច្ចក្នុងនាមជាប្រជាពលរដ្ឋមួយរូប។
- លុបបំបាត់ការសូកសំណូកក្នុងគោលបំណងប្រយោជន៍ផ្ទាល់ខ្លួន។

# ឯកសារយោង

# ឯកសារយោង

## ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ព្រះរាជក្រម នស/រកម/០១១៩/០០៤ ឆ្នាំ២០១៩ វិសោធនកម្មច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- អនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះនៅថ្ងៃទី១៤ ខែមករា ឆ្នាំ២០១៨ ស្ដីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- សេចក្ដីសម្រេចលេខ ០៩៦/០០១/២០០៨ កបធ.ច ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០០៨ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សេចក្ដីសម្រេចលេខ ០៤១/០០៣/២០០១ កបធ.ច ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០១ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់

## ឯកសារផ្សេងៗ

- សេចក្ដីណែនាំលេខ ០២ ស.ណ.ន ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១៨ ស្ដីពីការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- សេចក្ដីណែនាំលេខ ០១៥ ស.ណ.ន ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៩ ស្ដីពីការរៀបចំបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- សន្ធានុក្រម ឆ្នាំ២០០៨ ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- យុទ្ធសាស្ត្រចតុកោណ ឆ្នាំ២០១៨ ដំណាក់កាលទី៤
- សមាគមសាលាក្រាជូ ខែកុម្ភៈ ឆ្នាំ២០១៧ នីតិរដ្ឋបាលស្ដីពីវិមជ្ឈការនៅប្រទេសកម្ពុជា
- លេខាធិការដ្ឋាន គ.ជ.អ.ប ឆ្នាំ២០១០ សៀវភៅណែនាំ ស្ដីពីតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក
- សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ ឆ្នាំ២០២០ ការគ្រប់គ្រងរដ្ឋបាលក្រុង
- សេចក្ដីព្រាងលើទី១ ខែសីហា ឆ្នាំ២០១៩ កម្មវិធីជាតិ កំណែទម្រង់រដ្ឋបាលសាធារណៈ

- ឯកឧត្តម សក់ សេដ្ឋា ទស្សនទានអំពីកំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ
- គេហទំព័រ ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា
- គេហទំព័រ អង្គការទិន្នន័យអំពីការអភិវឌ្ឍ
- គេហទំព័រ ភូមិសាស្ត្រស្រុកខ្មែរ
- គេហទំព័រ លោក ឆេង សារី
- គេហទំព័រ លោក គង់ ឆាយឡេង
- គេហទំព័រ វិគីភិឌា
- គេហទំព័រ វប្បធម៌ទូទៅ

**សៀវភៅ**

- វចនានុក្រមខ្មែរសម្ដេចព្រះសង្ឃរាជជួន ណាត ភាគ១ ភាគ២
- កម្មវិធីទូរស័ព្ទដៃ វាចនានុក្រម សម្ដេចព្រះសង្ឃរាជជួន ណាត

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១៖ ប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ




## ឧបសម្ព័ន្ធទី២៖ ប្រព័ន្ធរដ្ឋបាលថ្នាក់រាជធានី-ខេត្ត



ឧបសម្ព័ន្ធទី៣៖ប្រព័ន្ធរដ្ឋបាលថ្នាក់ស្រុក-ក្រុង ឃុំ សង្កាត់






ឧបសម្ព័ន្ធទី៤៖ រចនាសម្ព័ន្ធក្រុមប្រឹក្សា



ឧបសម្ព័ន្ធទី៦៖ យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៤




ឧបសម្ព័ន្ធទី៧៖ អនុក្រឹត្យស្តីពី ការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ និងសេចក្តីណែនាំ ស្តីពីកាពង្រឹងកិច្ចដំណើរការ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ:...០៤...ស.ណន

# សេចក្ដីណែនាំ
# ស្ដីពី
# ការពង្រឹងកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការជាកំណែទម្រង់ផ្នែកអភិបាលកិច្ចដ៏មានសារៈសំខាន់របស់រាជរដ្ឋាភិបាល ដែលបានអនុវត្តចាប់តាំងពីឆ្នាំ២០០១មក និងបានបង្កើតនូវសមិទ្ធផលជាច្រើនពាក់ព័ន្ធទៅនឹងការកែសម្រួលឡើងវិញនូវរចនាសម្ព័ន្ធ ប្រព័ន្ធគ្រប់គ្រង និងនីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដោយឈរលើគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។ តាមរយៈការអនុវត្តកំណែទម្រង់នេះ រដ្ឋបាលថ្នាក់ក្រោមជាតិបានបំពេញតួនាទី និងការទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការលើកកម្ពស់អភិបាលកិច្ចល្អ ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងការផ្ដល់សេវាសាធារណៈនានាឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងដោះស្រាយបញ្ហាប្រឈមជាអាទិភាពនានានៅតាមមូលដ្ឋាន ដែលប្រការនេះបានចូលរួមចំណែកយ៉ាងមានប្រសិទ្ធភាពដល់ការលើកស្ទួយជីវភាពរស់នៅ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការត្រូវបានរៀបចំ អនុវត្ត និងដោះស្រាយបញ្ហាប្រឈមនានាផ្អែកតាមស្ថានភាពជាក់ស្ដែងរបស់កម្ពុជា និងផ្អែកតាមគោលនយោបាយ ច្បាប់ និងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ រហូតមកដល់ពេលនេះ កំណែទម្រង់នេះបានឈានចូលដល់ដំណាក់កាលកាន់តែស៊ីជម្រៅ ដោយតម្រូវឱ្យមានការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈនានា ដែលកំពុងមានការកើនឡើងយ៉ាងគំហុក ស្របពេលដែលស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ជាតិកំពុងមានការរីកចម្រើនកាន់តែខ្លាំង។

ក្នុងដំណាក់កាលដ៏សំខាន់នេះ តម្រូវឱ្យក្រសួង ស្ថាប័ននៅថ្នាក់ជាតិត្រូវផ្ទេរមុខងារ និងធនធានកាន់តែច្រើនឡើងបន្ថែមទៀតទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។ ទន្ទឹមគ្នានេះ ក៏តម្រូវឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបង្កើនការទទួលខុសត្រូវឱ្យបានកាន់តែសកម្មបន្ថែមទៀតក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តមុខងារដែលបានផ្ទេរឱ្យ ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ស្របតាមគោលនយោបាយ លិខិតបទដ្ឋាន និងស្ដង់ដាដែលបានកំណត់ជាធរមានក្នុងវិស័យនីមួយៗ។

ការផ្ទេរមុខងារ និងធនធានទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ គឺដើម្បីបង្វិតការធ្វើសេចក្តីសម្រេចចិត្ត ក្នុងការផ្តល់សេវាសាធារណៈតាមវិស័យនីមួយៗឱ្យទៅកៀកជិតប្រជាពលរដ្ឋ សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋបានកាន់តែឆាប់រហ័ស កាន់តែមានប្រសិទ្ធភាព និងគណនេយ្យភាព ស្របតាមស្ថានភាពជាក់ស្តែង និងមានលក្ខណៈផ្សេងៗគ្នារបស់មូលដ្ឋាននីមួយៗ។

ក្នុងន័យនេះ ដើម្បីធានាដល់ការលើកកម្ពស់ការដឹកនាំ ការគ្រប់គ្រង ការសម្របសម្រួល និងការគាំទ្រដល់ការអនុវត្តកិច្ចដំណើរការកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងដំណាក់កាលស៊ីជម្រៅនៅតាមក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ រាជរដ្ឋាភិបាលសូមធ្វើការណែនាំដូចខាងក្រោម ៖

## I. នៅថ្នាក់ជាតិ៖

ក្រសួងពាក់ព័ន្ធនានានៅថ្នាក់ជាតិ ត្រូវរៀបចំពង្រឹងយន្តការដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងស្ថាប័នរបស់ខ្លួនក្រោមការដឹកនាំ និងការទទួលខុសត្រូវដោយផ្ទាល់របស់រដ្ឋមន្ត្រីក្រសួងនីមួយៗ។ យន្តការនេះត្រូវមានរដ្ឋលេខាធិការ០១រូបជាអនុប្រធានប្រចាំការដើម្បីសម្របសម្រួលការងារប្រចាំថ្ងៃ និងត្រូវមានរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ និងទីប្រឹក្សាមួយចំនួន ព្រមទាំងថ្នាក់ដឹកនាំនៃអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាចំណុះក្រសួងជាសមាជិក។ ក្រសួងនីមួយៗត្រូវកំណត់យកអង្គភាពជាក់លាក់ណាមួយធ្វើជាលេខាធិការដ្ឋាននៃយន្តការនេះ។

ក្រសួងពាក់ព័ន្ធនីមួយៗត្រូវដាក់ចេញនូវសេចក្តីសម្រេច ដើម្បីបង្កើតយន្តការនេះ ដោយកំណត់អំពីសមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងារឱ្យបានជាក់លាក់ និងច្បាស់លាស់។

**យន្តការនេះត្រូវមានតួនាទី ភារកិច្ចសំខាន់ៗដូចខាងក្រោម៖**

- ដឹកនាំ សម្របសម្រួលកិច្ចដំណើរការនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងសាមីនីមួយៗ
- ដឹកនាំ សម្របសម្រួល និងគាំទ្រដល់ការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលពាក់ព័ន្ធនឹងវិស័យរបស់ខ្លួន ដើម្បីដាក់បញ្ចូលទៅក្នុងគម្រោងផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រសួងសាមីនីមួយៗ
- ដឹកនាំ សម្របសម្រួល និងគាំទ្រដល់អគ្គនាយកដ្ឋាន អង្គភាពចំណុះនានាក្នុងការអនុវត្តសកម្មភាពកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការស្របតាមផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ក្រសួងសាមីនីមួយៗ
- ដឹកនាំ សម្របសម្រួល និងសហការជាមួយក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីផ្តល់ការគាំទ្រដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការរៀបចំ ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យ ឬកិច្ចការជាអាទិភាពរបស់ក្រសួងសាមីនីមួយៗ
- តាមដាន ត្រួតពិនិត្យជាប្រចាំលើការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងសាមី

នីមួយៗ ស្របតាមសេចក្តីសម្រេចរួមដែលបានឯកភាពគ្នារវាងក្រសួងសាមីនីមួយៗជាមួយនឹងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប.) ស្តីពីការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ គ.ជ.អ.ប.

- រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការគ្រប់គ្រង ការចាត់ចែង និងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការរបស់ក្រសួងសាមីនីមួយៗ ដើម្បីផ្ញើជូន គ.ជ.អ.ប. តាមការកំណត់។

**យន្តការនេះត្រូវមានរបៀបរបបការងារជាទូទៅ ដូចខាងក្រោម៖**

- ត្រូវមានការប្រជុំជាទៀងទាត់០១ខែម្តង និងការប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការដែលស្ថិតក្រោមការទទួលខុសត្រូវរបស់ក្រសួងសាមីនីមួយៗ
- រដ្ឋមន្ត្រីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ករណីរដ្ឋមន្ត្រីអវត្តមាន ត្រូវផ្ទេរសិទ្ធិទៅឱ្យរដ្ឋលេខាធិការ ដែលជាអនុប្រធានប្រចាំការធ្វើជាប្រធានស្តីទី ហើយប្រធានស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- រដ្ឋមន្ត្រីអាចអញ្ជើញតំណាងក្រសួង ស្ថាប័ន រដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ឬតំណាងដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមកិច្ចប្រជុំរបស់ខ្លួនតាមការចាំបាច់។

## II. នៅថ្នាក់ក្រោមជាតិ៖

រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកនីមួយៗត្រូវរៀបចំបង្កើត "**គណៈកម្មការដឹកនាំការងារកំណែទម្រង់**"មួយជាបន្ទាន់ ដើម្បីដឹកនាំ សម្របសម្រួលកិច្ចដំណើរការជាទូទៅនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈកម្មការនេះមានសមាសភាពដូចខាងក្រោម ៖

**ក. រដ្ឋបាលរាជធានី**

| | |
|---|---|
| ១. អភិបាល | ប្រធាន |
| ២. អភិបាលរង ០១រូប | អនុប្រធានប្រចាំការ |
| ៣. នាយករដ្ឋបាល | សមាជិក |
| ៤. នាយកទីចាត់ការ និងប្រធានអង្គភាពនានានៃរដ្ឋបាលរាជធានី | សមាជិក |
| ៥. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦. ប្រធានមន្ទីរផែនការ | សមាជិក |
| ៧. ប្រធានមន្ទីរមុខងារសាធារណៈ | សមាជិក |
| ៨. ប្រធានមន្ទីរកិច្ចការនារី | សមាជិក |

៩. ប្រធានរតនាគារ សមាជិក

១០. អភិបាលខណ្ឌ សមាជិក

**ខ. រដ្ឋបាលខេត្ត**

១. អភិបាល ប្រធាន

២. អភិបាលរង ០១រូប អនុប្រធានប្រចាំការ

៣. នាយករដ្ឋបាល សមាជិក

៤. នាយកទីចាត់ការ និងប្រធានអង្គភាពនានានៃរដ្ឋបាលខេត្ត សមាជិក

៥. ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក

៦. ប្រធានមន្ទីរផែនការ សមាជិក

៧. ប្រធានមន្ទីរមុខងារសាធារណៈ សមាជិក

៨. ប្រធានមន្ទីរកិច្ចការនារី សមាជិក

៩. ប្រធានរតនាគារ សមាជិក

**គ. រដ្ឋបាលក្រុង ស្រុក**

១. អភិបាល ប្រធាន

២. អភិបាលរង ០១រូប អនុប្រធានប្រចាំការ

៣. នាយករដ្ឋបាល សមាជិក

៤. ប្រធានការិយាល័យ និងប្រធានអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក សមាជិក

៥. ប្រធានការិយាល័យផែនការ សមាជិក

៦. ប្រធានការិយាល័យកិច្ចការនារី សមាជិក

ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក គឺជាលេខាធិការដ្ឋាននៃគណៈកម្មការនេះ ដែលមានតួនាទីជួយគាំទ្រផ្នែកការងាររដ្ឋបាល និងការសម្របសម្រួលកិច្ចការប្រចាំថ្ងៃរបស់គណៈកម្មការនេះ។

ដើម្បីបំពេញបាននូវតួនាទីនេះ អភិបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវពិនិត្យឡើងវិញនូវមន្ត្រីក្នុងរចនាសម្ព័ន្ធនៃទីចាត់ការ និងការិយាល័យនេះ ដើម្បីចាត់តាំងមន្ត្រីដែលមានលក្ខណសម្បត្តិសមស្របមួយចំនួនបន្ថែមទៀតឱ្យមកបំពេញការងារនៅទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ដែលជាលេខាធិការដ្ឋាននៃ គណៈកម្មការនេះ។

ទីចាត់ការផែនការ និងវិនិយោគនៃរដ្ឋបាលរាជធានី ខេត្ត ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃរដ្ឋបាលក្រុង ស្រុក ដែលជាលេខាធិការដ្ឋាននៃគណៈកម្មការនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់ពីអភិបាលរងដែលជាអនុប្រធានប្រចាំការនៃគណៈកម្មការនេះ។

ការចំណាយសម្រាប់ការរៀបចំកិច្ចប្រជុំរបស់គណៈកម្មការ គឺជាបន្ទុករបស់រដ្ឋបាលរាជធានី ខេត្ត

ក្រុង ស្រុកសាមី។ ដោយឡែក ការចំណាយសម្រាប់ការចុះតាមដាន ត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍នានា នៅតាមមូលដ្ឋាន គឺជាបន្ទុករបស់អង្គភាពសាមីនីមួយៗនៃសមាជិករបស់គណៈកម្មការ ។

អភិបាលរាជធានី ខេត្ត ក្រុង ស្រុកត្រូវចេញសេចក្តីសម្រេចស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃ គណៈកម្មការដឹកនាំការងារកំណែទម្រង់រាជធានី ខេត្ត ក្រុង ស្រុករបស់ខ្លួន ដែលកំណត់អំពីសមាសភាព តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មការ។

**គណៈកម្មការនេះមានតួនាទី និងភារកិច្ចសំខាន់ៗដូចខាងក្រោម៖**

- ដឹកនាំ សម្របសម្រួលកិច្ចដំណើរការជាទូទៅនៃការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការស្របតាមច្បាប់ និងលិខិតបទដ្ឋានដែលបានកំណត់
- ដឹកនាំ សម្របសម្រួលកិច្ចដំណើរការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដើម្បីដាក់បញ្ចូលទៅ ក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកសាមីនីមួយៗ
- ដឹកនាំ សម្របសម្រួល គាំទ្រ តាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ច របស់ខ្លួន
- ទំនាក់ទំនងជាមួយក្រសួង ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ដើម្បីសម្របសម្រួល និងកៀរគរការគាំ ទ្រដល់ការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សម្របសម្រួល តាមដាន ត្រួតពិនិត្យ និងផ្តល់អន្តរាគមន៍ផ្នែករដ្ឋបាល និងបច្ចេកទេសដល់រដ្ឋ បាលក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់
- សម្របសម្រួល ដោះស្រាយបញ្ហាប្រឈមពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្របសម្រួល កៀរគរការចូលរួម និងការគាំទ្រនានាពីមន្ទីរ អង្គភាពជំនាញ អង្គការសង្គមស៊ីវិល សហគមន៍មូលដ្ឋាន និងផ្នែកឯកជនក្នុងការអនុវត្តកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈ ការក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្របសម្រួលការគ្រប់គ្រង និងការធ្វើបច្ចុប្បន្នភាពប្រព័ន្ធទិន្នន័យនានាពាក់ព័ន្ធនឹងព័ត៌មាន នានារបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- គ្រប់គ្រងមធ្យោបាយ ឧបករណ៍ សម្ភារ និងបរិក្ខារនានារបស់ គ.ជ.អ.ប. ដែលបានបែងចែក ឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗប្រើប្រាស់សម្រាប់ការងារកំណែទម្រង់
- សម្របសម្រួល និងគាំទ្រដល់ការអនុវត្តកម្មវិធីប្រឡងប្រណាំងអំពីការបំពេញការងាររបស់រដ្ឋ បាលថ្នាក់ក្រោមជាតិ
- ក្នុងការដឹកនាំ សម្របសម្រួល ករណីមានការពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់មន្ទីរ អង្គភាព ទីចាត់

ការ ឬថ្នាក់រដ្ឋបាលណាមួយ គណៈកម្មការត្រូវណែនាំដល់មន្ទីរ អង្គភាព ទីចាត់ការ ឬថ្នាក់រដ្ឋបាលនោះ ឱ្យចាត់ចែងអនុវត្តស្របតាមតួនាទី ភារកិច្ចដែលបានកំណត់ ដើម្បីលើកកម្ពស់សមត្ថភាព និងការទទួលខុសត្រូវរបស់ស្ថាប័ន ដោយមិនត្រូវចាត់ចែងជំនួសឡើយ ហើយត្រូវតាមដានត្រួតពិនិត្យការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ស្ថាប័នទាំងនោះ

- រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាព និងបញ្ហាប្រឈមនៃការអនុវត្តផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំនៃកម្មវិធីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមការកំណត់ ដើម្បីរាយការណ៍ជូនគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន ដើម្បីផ្ញើជូនមកលេខាធិការដ្ឋាន គ.ជ.អ.ប.។

**គណៈកម្មការមានរបៀបរបបការងារ ដូចខាងក្រោម៖**

- ទទួលខុសត្រូវ និងមានគណនេយ្យភាពចំពោះគណៈអភិបាល និងក្រុមប្រឹក្សារបស់ខ្លួន
- មានរបបប្រជុំជាទៀងទាត់០១ខែម្ដង និងប្រជុំតាមការចាំបាច់ ដើម្បីដឹកនាំ សម្របសម្រួល តាមដានត្រួតពិនិត្យ និងដោះស្រាយបញ្ហាប្រឈមនានា ក្នុងការអនុវត្តការងារកំណែទម្រង់
- ប្រធានគណៈកម្មការ ជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំរបស់គណៈកម្មការ។ ករណីប្រធានអវត្តមាន ត្រូវផ្ទេរសិទ្ធិជាលាយល័ក្ខណ៍អក្សរទៅឱ្យអនុប្រធានជាប្រធានស្ដីទី ហើយប្រធានស្ដីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ
- កិច្ចប្រជុំរបស់គណៈកម្មការអាចប្រព្រឹត្តទៅបាន លុះត្រាតែមានវត្តមានសមាជិកលើសពីពាក់កណ្ដាលនៃចំនួនសមាជិកគណៈកម្មការទាំងមូល
- ប្រធានគណៈកម្មការអាចអញ្ជើញតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ប្រធានមន្ទីរ អង្គភាពជំនាញផ្សេងៗទៀត ឬតំណាងអង្គការសង្គមស៊ីវិល ផ្នែកឯកជន និងអ្នកពាក់ព័ន្ធនានា ដើម្បីចូលរួមកិច្ចប្រជុំរបស់គណៈកម្មការ តាមការចាំបាច់
- គ្រប់កិច្ចប្រជុំរបស់គណៈកម្មការ ត្រូវមានកំណត់ហេតុដែលរៀបចំដោយលេខាធិការដ្ឋានរបស់គណៈកម្មការ និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។
- ក្នុងករណីចាំបាច់ គណៈកម្មការអាចស្នើសុំអន្តរាគមន៍ផ្នែកបច្ចេកទេសពីលេខាធិការដ្ឋាន គ.ជ.អ.ប.។

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវតាមដានត្រួតពិនិត្យការរៀបចំឡើងវិញនូវយន្តការទាំងនេះ និងធ្វើការសម្របសម្រួលលើការអនុវត្តការងារកំណែទម្រង់ ព្រមទាំងត្រូវធ្វើសេចក្ដីរាយការណ៍ជូនរាជរដ្ឋាភិបាលអំពីសមិទ្ធផល និងបញ្ហាប្រឈមនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះនៅតាមក្រសួង ស្ថាប័នពាក់ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនានា។

ទទួលបានសេចក្តីណែនាំនេះ គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងពាក់ព័ន្ធនានា និងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវទទួលបន្ទុកអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ១២ រោច ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៩ ខែកក្កដា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក
- រាជកិច្ច

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២៤០ អនក្រ.បក

ចូល លេខ: ៥០ ថ្ងៃទី០៤ ខែ០១ ឆ្នាំ២០១៧ ម៉ោង ៩:០១

# អនុក្រឹត្យ

## ស្តីពី

## ការផ្ទេរប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩៩៩/១១ ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា៥១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៣/០០៤ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការធ្វើវិសោធនកម្មមាត្រា៩ និងមាត្រា១០នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ២១៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ និងក្រុមប្រឹក្សា គណៈអភិបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទីភារកិច្ច និងទំនាក់ទំនងរបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ២៨៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីនីតិវិធីសម្រាប់ការរៀបចំ ការកែប្រែ និងការលុបចោលដីការបស់ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ
- យោងតាមសំណើប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះមានគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងប្រសិទ្ធផលនៃការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ តាមរយៈការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុកនិងការកែសម្រួលនីតិវិធីក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ។

**មាត្រា២.-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពី ៖

- ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ លើកលែងតែមន្ត្រីរាជការស៊ីវិលក្រោមឱវាទនៃអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានពន្ធដារ សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ និងមន្ត្រីរាជការដែលស្ថិតក្រោមបទប្បញ្ញត្តិដោយឡែករបស់រាជរដ្ឋាភិបាល។

**មាត្រា៤.-**

វាក្យសព្ទបច្ចេកទេសនៅក្នុងអនុក្រឹត្យនេះមានន័យដូចតទៅ៖

- ប្រសិទ្ធផល សំដៅដល់លទ្ធផលចុងក្រោយ ឬគុណភាពនៃលទ្ធផលដែលមានឥទ្ធិពល ឬផលប៉ះពាល់រយៈពេលវែង។
- បុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ សំដៅដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិករបស់មន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួង ស្ថាប័នដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។
- បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ សំដៅដល់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានជ្រើសរើស និងតែងតាំងដោយរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលបានផ្ទេរតាមដំណើរការនៃការផ្ទេរមុខងារទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឬចាត់តាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិ ឱ្យទៅបំពេញការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងបុគ្គលិកជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលបានជ្រើសរើសដោយរដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី២

## ការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា៥.-**

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក រួមមាន៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងនាយកទីចាត់ការ ឬ ប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្តសម្រាប់រដ្ឋបាលរាជធានី ខេត្ត។
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាលនិងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលក្រុង ស្រុក សម្រាប់រដ្ឋបាលក្រុង ស្រុក
- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។

**មាត្រា៦.-**

ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលមិនតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក រួមមាន៖

- ការជ្រើសរើសបុគ្គលិក
- ការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់កម្មសិក្សា
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងចាប់ពីនាយករងទីចាត់ការ ឬអនុប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលនៃរដ្ឋបាលរាជធានី ខេត្តចុះក្រោមសម្រាប់រដ្ឋបាលរាជធានី ខេត្ត។ ដោយឡែកសម្រាប់រដ្ឋបាលរាជធានីក្រៅពីមុខតំណែងខាងលើនេះត្រូវរួមបញ្ចូលទាំងមុខតំណែងចាប់ពីនាយករងរដ្ឋបាលនៃរដ្ឋបាលខណ្ឌចុះក្រោម
- ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងចាប់ពីអនុប្រធានការិយាល័យក្រុង ស្រុក ឬអនុប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែលចុះក្រោមសម្រាប់រដ្ឋបាលក្រុង ស្រុក
- ការដំឡើងថ្នាក់និងឋានន្តរស័ក្តិ

- ការផ្លាស់ប្ដូរទីកន្លែងធ្វើការងារពីអង្គភាពមួយទៅអង្គភាពមួយនៅក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការដាក់ឱ្យស្ថិតនៅក្រៅក្របខ័ណ្ឌដើម ឬការដាក់ឱ្យនៅក្រៅតំណែង
- ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- ការដាក់ឱ្យចូលបម្រើការងារឡើងវិញ
- ការដាក់ឱ្យចូលនិវត្តន៍ ការដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈ និងការស្នើសុំលាឈប់ពីការងារ
- ការដាក់ទណ្ឌកម្មខាងវិន័យ
- ការផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀតនិងការផ្ទេររវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួង ស្ថាប័នថ្នាក់ជាតិ
- កិច្ចការពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិកផ្សេងទៀត។

**មាត្រា៧ .-**

ក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវរៀបចំ និងដាក់ចេញនូវសេចក្ដីណែនាំស្ដីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

## ជំពូកទី៣
## ការតែងតាំង និងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

**មាត្រា៨ .-**

អភិបាលរាជធានី ខេត្ត ដោយមានការឯកភាពពីគណៈអភិបាលរបស់ខ្លួន ត្រូវលើកសំណើតែងតាំងនិងបញ្ចប់មុខតំណែងប្រធានមន្ទីរ ឬប្រធានអង្គភាពជំនាញថ្នាក់ប្រហាក់ប្រហែលរបស់ក្រសួងដែលបំពេញការងារនៅរាជធានី ខេត្ត មករដ្ឋមន្ត្រីសាមី ដើម្បីពិនិត្យសម្រេច។

**មាត្រា៩ .-**

ត្រូវបានធ្វើប្រតិភូកម្មសិទ្ធិអំណាចដល់គណៈអភិបាលរាជធានី ខេត្ត ក្នុងការតែងតាំងនិងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានារបស់ក្រសួងដែលបំពេញការងារនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចាប់ពីអនុប្រធានមន្ទីរឬអនុប្រធានអង្គភាពថ្នាក់ប្រហាក់ប្រហែលចុះក្រោមតាមសំណើរបស់ប្រធានមន្ទីរឬអង្គភាពសាមី។

**មាត្រា១០ .-**

ក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិត្រូវរៀបចំ និងដាក់ចេញនូវសេចក្ដីណែនាំស្ដីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការតែងតាំងនិងការបញ្ចប់មុខតំណែងគ្រប់គ្រងរបស់មន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៤
## ការរៀបចំ និងការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តកូត ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ

**មាត្រា១១.-**

រាល់សេចក្តីសម្រេចនានាពាក់ព័ន្ធការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ តាមការកំណត់នៃព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនិងអនុក្រឹត្យនេះ រដ្ឋបាលថ្នាក់ក្រោមជាតិមានសមត្ថកិច្ច ត្រូវរៀបចំនិងដាក់ចេញដីកាមានលក្ខណៈជាឯកត្តកូត។

ដីកាដែលមានលក្ខណៈជាឯកត្តកូត ត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុកមានសមត្ថកិច្ច បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សា ឬបន្ទាប់ពីទទួលបានការឯកភាពពីគណៈអភិបាល យោងតាមករណីដូចមានចែងក្នុងមាត្រា១២ និង១៣នៃអនុក្រឹត្យនេះ។

**មាត្រា១២.-**

ការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តកូតសម្រាប់អនុវត្តនូវសិទ្ធិអំណាចរបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកដូចមានចែងក្នុងមាត្រា៦ និងមាត្រា៩នៃអនុក្រឹត្យនេះ ត្រូវចុះហត្ថលេខាដោយអភិបាលមានសមត្ថកិច្ច បន្ទាប់ពីមានការឯកភាពពីគណៈអភិបាល។

**មាត្រា១៣.-**

ការដាក់ចេញដីកាដែលមានលក្ខណៈជាឯកត្តកូតសម្រាប់ការគ្រប់គ្រងបុគ្គលិកដែលតម្រូវឱ្យមានការអនុម័តពីក្រុមប្រឹក្សានៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ដូចមានចែងនៅក្នុងមាត្រា៥នៃអនុក្រឹត្យនេះ ត្រូវចុះហត្ថលេខាដោយអភិបាលរាជធានី ខេត្ត ក្រុង ស្រុក បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សា។

## ជំពូកទី៥
## ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃ

**មាត្រា១៤.-**

ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ត្រូវតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងផ្តល់គោលការណ៍ណែនាំដល់គណៈអភិបាលដើម្បីលើកកម្ពស់ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព យុត្តិធម៌ និងសមធម៌ក្នុងការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក។

គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវធ្វើរបាយការណ៍ជាទៀងទាត់ជូនកិច្ចប្រជុំក្រុមប្រឹក្សាអំពីស្ថានភាពនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក។

ក្នុងករណីគណៈអភិបាល បានដាក់ចេញនូវដីកាសម្រាប់ការគ្រប់គ្រងបុគ្គលិករដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក មិនស្របតាមគោលការណ៍ បែបបទ និងនីតិវិធីជាធរមាន ក្រុមប្រឹក្សា ត្រូវផ្តល់ការណែនាំដល់គណៈអភិបាលដើម្បីកែតម្រូវ ឬលុបចោលដីកាទាំងនោះ។

ក្នុងករណីដែលគណៈអភិបាលមិនព្រមចាត់វិធានការកែតម្រូវ ឬលុបចោលដីកាតាមការណែនាំក្រុមប្រឹក្សាត្រូវធ្វើសេចក្តីរាយការណ៍ជាលាយលក្ខណ៍អក្សរជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីមានវិធានការ។

**មាត្រា១៥ ._**

រាល់ដីកាពាក់ព័ន្ធនឹងការគ្រប់គ្រងបុគ្គលិក គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ត្រូវបញ្ជូនមក មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត និង ចម្លងជូនក្រសួង ស្ថាប័ន អង្គភាពសាមី ដោយមានភ្ជាប់ឯកសារ ពាក់ព័ន្ធ។

ក្នុងករណីមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ពិនិត្យឃើញថាដីកាខាងលើមិនសមស្របនឹងរចនាសម្ព័ន្ធមុខតំណែងនិងចំនួនមុខតំណែងគ្រប់គ្រង ឬ មិនស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិលក្នុងតារាងទូទាត់បៀវត្សឡើយ ហើយត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរដោយមានបញ្ជាក់អំពីមូលហេតុជូនអភិបាលនៃរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ និង ប្រធានអង្គភាពសាមី ក្នុងរយៈពេលយ៉ាងយូរ០៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានដីកាដើម្បីមានចំណាត់ការឱ្យសមស្របតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា១៦ ._**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងក្រសួងមុខងារសាធារណៈត្រូវសម្របសម្រួលជាមួយក្រសួង ស្ថាប័ននានាដើម្បីរៀបចំនូវយន្តការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តសិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មតាមស្មារតីនៃអនុក្រឹត្យនេះ ដើម្បីធានាថា ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុកអនុវត្តអំណាចក្នុងការគ្រប់គ្រងបុគ្គលិកដែលបំពេញការងារនៅថ្នាក់ក្រោមជាតិអនុលោមតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាន គតិយុត្តជាធរមាន និងគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សមធម៌ និងអព្យាក្រឹតភាពនៃមន្ត្រីរាជការស៊ីវិល។

## ជំពូកទី៦

## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៧ ._**

បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីរាជការស៊ីវិលនៃមន្ទីរ អង្គភាព និងការិយាល័យជំនាញនានានៃក្រសួងដែលបំពេញការងារនៅថ្នាក់ក្រោមជាតិក្រោមបទប្បញ្ញត្តិនានានៃអនុក្រឹត្យនេះមិនត្រូវអនុវត្តចំពោះការគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំង ឬចាត់តាំងដោយរាជរដ្ឋាភិបាល ឬដោយក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅបំពេញការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវអនុវត្តតាមបែបបទ និងនីតិវិធីជាធរមាន។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា១៨ ._**

អនុក្រឹត្យលេខ៤៩៧ អនក្រ.បក ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការផ្ទេរប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៩ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃពុធ ១០កើត ខែ មិគសិរ ឆ្នាំ រកា ព.ស២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែ ១១ គ.ស២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**និងជាប្រធាន គ.ជ.អ.ប**

**សម្តេចក្រឡាហោម ស ខេង**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**
**និងជាប្រធានគណៈកម្មាធិការ**
**កំណែទម្រង់រដ្ឋបាលសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ